# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

**សំណុំរឿងលេខ** : ០០៣/០៧-០៩-២០០៩-អវតក/កសចស (អ.ប.ជ៣៧)
**ដាក់ទៅ** : អង្គបុរេជំនុំជម្រះ
**ថ្ងៃដាក់** : ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១
**ភាគីអ្នកដាក់** : សហព្រះរាជអាជ្ញាអន្តរជាតិ
**ភាសាដើម** : អង់គ្លេស

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 21-Jun-21, 13:55
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** សាធារណៈ:
**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គបុរេជំនុំជម្រះ:** សាធារណៈ:/Public
**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**
**ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:**
**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**
**ហត្ថលេខា:**

---

## សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យមិនបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះ នៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣

---

**អ្នកដាក់ឯកសារ:**
លោកស្រី Brenda J. HOLLIS
**សហព្រះរាជអាជ្ញាអន្តរជាតិ**

**ចម្លងជូន:**
លោកស្រី ជា លាង
**សហព្រះរាជអាជ្ញាជាតិ**

**អ្នកទទួលឯកសារ:**
**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន៍យ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

**សហមេធាវី មាស មុត:**
លោក អាង ឧត្តម
លោក Michael KARNAVAS

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ ក្នុងសំណុំរឿង ០០៣**

## I. សេចក្តីផ្តើម

1. សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") សូមស្នើដល់អង្គបុរេជំនុំជម្រះ ("អ.ប.ជ") បិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០៣ តាមរយៈ៖ (i) ការចេញសេចក្តីសម្រេចជាស្ថាពរមួយដែលឯកភាពគ្នា ដោយបញ្ជាក់ថា មាស មុត ត្រូវបានចោទប្រកាន់ ហើយបង្គាប់ឱ្យបញ្ជូនខ្លួនគាត់ទៅជំនុំជម្រះតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះ[1] ស្របតាមការសម្រេចជាឯកច្ឆន្ទនៅក្នុងសេចក្តីពិចារណារបស់ខ្លួន[2] ដែលថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព និងវិធាន៧៧(១៣) នៃវិធានផ្ទៃក្នុង[3] និង (ii) ចាត់វិធានការរដ្ឋបាលចាំបាច់ទាំងអស់ដើម្បីបង្គាប់ទៅផ្នែកគ្រប់គ្រងតុលាការ ("CMS") ឱ្យបញ្ជូនសេចក្តីពិចារណា ជាមួយនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទៅអង្គជំនុំជម្រះសាលាដំបូង ("អ.ជ.ស.ដ") ហើយអនុញ្ញាតឱ្យ អ.ជ.ស.ដ ចូលពិនិត្យមើលសំណុំរឿងដែលនៅសេសសល់ជាអេឡិចត្រូនិក។

2. ស.ព.អ សូមស្នើឱ្យ អ.ប.ជ ចាត់វិធានការនេះដើម្បីដោះស្រាយបញ្ហាទាំងអស់ដែលមាននៅចំពោះមុខខ្លួនតាមរបៀបមួយដែលស្របតាមច្បាប់ អ.វ.ត.ក ប៉ុណ្ណោះ តាមការបញ្ជូនសំណុំរឿងនេះទៅជំនុំជម្រះដើម្បីឱ្យមានប្រសិទ្ធិភាពចំពោះការព្រមព្រៀងជាឯកច្ឆន្ទរបស់ខ្លួនដែលថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃសំណុំរឿង ០០៣ មានសុពលភាព។

3. បន្ទាប់ពីការចេញសេចក្តីពិចារណារបស់ អ.ប.ជ មក សំណុំរឿង ០០៣ ហាក់ដូចជាបានឈានដល់ការជាប់គាំងផ្នែកនីតិវិធីមានលក្ខណៈដូចគ្នាទៅនឹងការជាប់គាំងកាលពីមុនៗក្នុងសំណុំរឿង ០០៤/២ ដែរ។ វាជាកត្តាកំណត់មួយដែលត្រូវតែបិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃសំណុំរឿង០០៣ *តាមរយៈការកំណត់តាមផ្លូវតុលាការ* ស្របតាមអត្ថន័យធម្មតានៃច្បាប់របស់តុលាការនេះ ដែលកំណត់អាណត្តិឱ្យបញ្ជូនសំណុំរឿងនេះទៅ អ.ជ.ស.ដ ជាបន្ទាន់។ មានតែការធ្វើដូច្នេះទេទើបអាចបញ្ចៀស អ.ប.ជ ពីការបង្កើតឱ្យមានអពលានៃប្រពន្ធច្បាប់ព្រហ្មទណ្ឌបាន និងការពារសិទ្ធិ និងផលប្រយោជន៍គ្រប់ភាគី*ទាំងអស់* ដោយការស្តារនូវភាពមិនប្រាកដប្រជាផ្លូវច្បាប់ឡើងវិញ និងធានាបាននូវរដ្ឋបាលតុលាការ

---

[1] ឯកសារ **D267** ដីកាដំណោះស្រាយ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ")។

[2] ឯកសារ **D266/27** & **D267/35** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១ ("សេចក្តីពិចារណា")។

[3] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) ដែលបានកែប្រែ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធាន" ឬ "វិធានផ្ទៃក្នុង") វិធាន៧៧(១៣) ("សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះតម្រូវឱ្យមានសំឡេងគាំទ្រជាវិជ្ជមានពីចៅក្រម៤(បួន)រូបយ៉ាងតិច")។

មួយដែលល្អ ត្រឹមត្រូវយុត្តិធម៌ និងឆាប់រហ័ស នៅក្នុងក្របខណ្ឌគតិយុត្តិរបស់តុលាការនេះ។

## II. ប្រវត្តិនីតិវិធីពាក់ព័ន្ធ

4. នៅថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១ អ.ប.ជ បានចេញ "សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ"[4] របស់ខ្លួន ក្នុងនោះសុពលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលឲ្យបញ្ជូនខ្លួន មាស មុត ទៅជំនុំជម្រះនោះត្រូវបានតម្កល់ដោយចៅក្រម អ.ប.ជ ទាំងប្រាំរូប[5]។ ជាការបន្ថែមចៅក្រមអន្តរជាតិបានរកឃើញថា ដីកាសម្រេចលើកលែងចោទប្រកាន់[6]ត្រូវបានទុកជាមោឃៈ និងគ្មានសុពលភាពដោយសារវិការៈនៃខ្លឹមសារ[7] និងនីតិវិធី[8]។

---

[4] ឯកសារ **D266/27** & **D267/35** សេចក្តីពិចារណា។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") បានចេញដីកាដំណោះស្រាយមួយដោយចោទប្រកាន់ មាស មុត ចំពោះអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ និងការរំលោភក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ និងឲ្យបញ្ជូនខ្លួនគាត់ទៅជំនុំជម្រះ ចំណែកចៅក្រមស៊ើបអង្កេតជាតិ ("ស.ច.ស.ជ") បានចេញដីកាដំណោះស្រាយមួយដោយសម្រេចលើកលែងចោទប្រកាន់រូបគាត់ ឈរលើមូលដ្ឋានថា គាត់មិនស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក។

[5] ឯកសារ **D266/27** & **D267/35** សេចក្តីពិចារណា យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន៍យ ថុល និងចៅក្រម ហួត វុទ្ធី ("យោបល់ចៅក្រមជាតិ") កថាខណ្ឌ ១១៥ ("ន័យដូចចែងក្នុងវិធាន ៧៧(១៣) ខាងលើ ដីកាដំណោះស្រាយទាំងពីរមានតម្លៃស្មើគ្នា *ត្រូវតម្កល់ទុកជាបានការដូចគ្នា មានសុពលភាពដូចគ្នា*" (សង្កត់ន័យដើម)។ យោបល់របស់ចៅក្រម Olivier Beauvallet និងចៅក្រម Kang Jin Baik ("យោបល់ចៅក្រមអន្តរជាតិ") កថាខណ្ឌ ១១៩, ២៦២, ២៨៤ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាពជាសារធាតុ ហើយមានអនុលោមភាពជាមួយក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក" (ដកស្រង់ត្រង់កថាខណ្ឌ ២៨៤)), ៣៣៩-៣៤០ (តម្កល់សេចក្តីសម្រេចរបស់ ស.ច.ស.អ ថា មាស មុត គឺជាជនម្នាក់នៅក្នុងចំណោមជនដែលទទួលខុសត្រូវខ្ពស់បំផុត និងថា បើដូច្នេះ ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក), ៣៤២-៣៤៥ (រកឃើញថា មានការសម្រេចជាឯកច្ឆន្ទនៅក្នុងរឿងក្តីនេះ ថ្វីបើសម្រាប់មូលហេតុមិនដូចគ្នាក្តី ចៅក្រមជាតិ និងអន្តរជាតិនៃអង្គជំនុំជម្រះបានរកឃើញស្របគ្នាថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព ហើយបានតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះជាឯកច្ឆន្ទ), ផ្នែកសម្រេចសេចក្តី ត្រង់ EN 01667089, FR 01667264, KH 01667480។

[6] ឯកសារ **D266** ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ("ដីកាសម្រេចលើកលែងចោទប្រកាន់")។

[7] ឯកសារ **D266/27** & **D267/35** សេចក្តីពិចារណា យោបល់ចៅក្រមអន្តរជាតិ កថាខណ្ឌ ១១៩, ២២៦-២៥០, ២៨៤ ផ្នែកសម្រេចសេចក្តី ត្រង់ EN 01667089, FR 01667264, KH 01667480 (តម្កល់ទឡ្ហីករណ៍បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ទឡ្ហីករណ៍ ខ និង គ និងបានសម្រេចថា សំណុំរឿង ០០៣ មានដីកាសម្រេចលើកលែងចោទប្រកាន់មិនពេញលេញដោយធ្វើមិនដឹងមិនឮចំពោះភ័ស្តុតាងអាយុជាងប្រាំពីរឆ្នាំដែលបានដាក់នៅក្នុងសំណុំរឿង តាំងពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ និងអង្គហេតុចោទប្រកាន់ដែល ស.ព.អ បានប្តឹងយ៉ាងត្រឹមត្រូវទៅ ស.ច.ស.ជ។ ចៅក្រមអន្តរជាតិបានរកឃើញថា ដីកាសម្រេចលើកលែងចោទប្រកាន់ដែលមិនពេញលេញនេះ គឺពុំមានសុពលភាពទេបើតាមអត្ថន័យនៃវិធាន ៦៧ ហើយត្រូវបានទុកជាមោឃៈ និងយក

5. ដោយសារចៅក្រម "មិនអាចរកសំឡេងភាគច្រើនលើសលុបនៃសំឡេងគាំទ្រចំនួនបួនតាមការកំណត់ដើម្បីឈានទៅដល់ការធ្វើសេចក្តីសម្រេចមួយលើអង្គសេចក្តី 'ផ្អែកលើសំអាងហេតុរួមបាន'"[9] ទើបចៅក្រម អ.ប.ជ បានចេញមតិយោបល់ដាច់ដោយឡែកស្តីពីអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍របស់ភាគី និងសុពលភាពនៃដីកាដំណោះស្រាយទាំងពីរ បន្ទាប់មកបានថ្លែងអំពីការយល់ឃើញដាច់ដោយឡែករបស់ពួកគាត់តាមអ្វីដែលជាការកំណត់ចុងក្រោយនៃដំណាក់កាលមុនការជំនុំជម្រះនៃសំណុំរឿង ០០៣ ដែលគួរតែត្រូវធ្វើ។ ចៅក្រមជាតិមានមតិយោបល់ថា បន្ទាប់ពីដំណាក់កាលនៃបណ្តឹងឧទ្ធរណ៍ ដោយសារដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងដីកាសម្រេចលើកលែងចោទប្រកាន់ "រក្សាបាននូវតម្លៃស្មើគ្នាដដែល" សំណុំរឿងប្រឆាំងនឹង មាស មុត "គួរតែតម្កល់ទុកនៅបណ្ណសារនៃ អ.វ.ត.ក"[10]។ ចៅក្រមអន្តរជាតិមានយោបល់ថា តាមស្មារតីនៃ (i) ការរកឃើញរបស់ខ្លួនដែលថា ដីកាសម្រេចលើកលែងចោទប្រកាន់ត្រូវបានចាត់ទុកជាមោឃៈ និងគ្មានសុពលភាព និង (ii) ការសម្រេចជាឯកច្ឆន្ទ *តាមព្រឹត្តន័យ* ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព "អង្គជំនុំជម្រះសាលាដំបូងត្រូវបានប្តឹងឲ្យទទួលយកសំណុំរឿង ០០៣ ដោយឈរលើមូលដ្ឋានដីកាបញ្ជូនរឿងទៅជំនុំជម្រះ អនុលោមតាមវិធាន ៧៧(១៣)"[11]។

6. នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ផ្អែកតាមការតម្កល់ជាឯកច្ឆន្ទនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ចៅក្រម អ.ប.ជ អនុលោមតាមវិធាន ៧៧(១៣)(ខ) ស.ព.អ បានស្នើឲ្យសហចៅក្រមស៊ើបអង្កេត

---

ជាការពុំបានឡើយដោយផ្អែកតែលើចំណុចនេះ)។ *សូមមើលផងដែរ* កថាខណ្ឌ ៣៣៩ (ដែលសន្និដ្ឋានថា ស.ច.ស.ជ "មានកំហុសអង្គច្បាប់ និងអង្គហេតុ ក្នុងការវាយតម្លៃចំពោះភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទ ឬដែលត្រូវបានចោទប្រកាន់លើ មាស មុត និងនៅក្នុងការពិនិត្យឡើងវិញលើកម្រិតនៃការទទួលខុសត្រូវរបស់លោក មាស មុត ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។"។

[8] ឯកសារ **D266/27** & **D267/35** សេចក្តីពិចារណា យោបល់ចៅក្រមអន្តរជាតិ កថាខណ្ឌ ២៥៥-២៦២, ២៨៤ ផ្នែកសម្រេចសេចក្តី ត្រង់ EN 01667089, FR 01667264, KH 01667480 (រកឃើញថា ដីកាសម្រេចលើកលែងចោទប្រកាន់ ត្រូវទុកជាមោឃៈនិងគ្មានសុពលភាព ដោយសារដីកានេះបានចេញបំពានលើគោលការណ៍នៃការបន្តកិច្ចស៊ើបសួរ និងការចោទប្រកាន់ដែលមាននៅក្នុងក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក)។

[9] ឯកសារ **D266/27** & **D267/35** សេចក្តីពិចារណា កថាខណ្ឌ ១១០ (ជាឯកច្ឆន្ទ) ផ្នែកសម្រេចសេចក្តី ត្រង់ EN 01666984, FR 01667141, KH 01667329 (ដកស្រង់ក្នុងកថាខណ្ឌ ១១០) (ជាឯកច្ឆន្ទ)។

[10] ឯកសារ **D266/27** & **D267/35** សេចក្តីពិចារណា យោបល់ចៅក្រម កថាខណ្ឌ ១១៧-១១៨ ផ្នែកសម្រេចសេចក្តី ត្រង់ EN 01666986, FR 01667144, KH 01667332។

[11] ឯកសារ **D266/27** & **D267/35** សេចក្តីពិចារណា យោបល់ចៅក្រមអន្តរជាតិ កថាខណ្ឌ ៣៤២-៣៤៣ ផ្នែកសម្រេចសេចក្តីត្រង់ EN 01667089, FR 01667264, KH 01667480 (ដកស្រង់ត្រង់ផ្នែកសម្រេចសេចក្តី)។

("ស.ច.ស") បញ្ជូនសំណុំរឿងទៅ អ.ជ.ស.ដ ស្របតាមវិធាន ៧៧(១៤)[12]។ តាមរយៈការទទួលបាន ចម្លើយតបរបស់ មាស មុត តែជាភាសាអង់គ្លេស[13] និងដោយមិនរង់ចាំការឆ្លើយតបរបស់ ស.ព.អ[14] ស.ច.ស បានបដិសេធលើសំណើរបស់ ស.ព.អ[15]។

7. នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២១ ស.ព.អ បានស្នើសុំការពន្យារពេលដើម្បីដាក់បញ្ជីសាក្សី និងអ្នកជំនាញរបស់ខ្លួនស្របតាមវិធាន ៨០[16]។ នៅក្នុងចម្លើយតប ក្រឡាបញ្ជី អ.ជ.ស.ដ តាមការស្នើសុំពីប្រធាន អ.ជ.ស.ដ បានប្រាប់មកភាគីថា" [អ.ជ.ស.ដ] មិនត្រូវបានជូនដំណឹងអំពី "សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ"ទេ ហើយក៏មិនបានទទួលសំណុំរឿង"ដែរ។ អាស្រ័យហេតុនេះ [អ.ជ.ស.ដ] មិនទទួលធ្វើការប្រាស្រ័យទំនាក់ទំនងពីភាគីទេ (សូមមើលផងដែរ វិធាន ៧៧/១៤ នៃវិធានផ្ទៃក្នុង)"[17]។

8. នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ អ.ប.ជ បានចេញសេចក្តីពិចារណារបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច ស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[18]។

---

[12] ឯកសារ **D270** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅកាន់សហចៅក្រមស៊ើបអង្កេតសុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ("សំណើរបស់ ស.ព.អ ទៅ ស.ច.ស")។

[13] ឯកសារ **D270/4** ចម្លើយរបស់ មាស មុត តបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅកាន់សហចៅក្រមស៊ើបអង្កេត សុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១ (ភាសាអង់គ្លេស បានដាក់នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១ ចំណែកភាសាខ្មែរ បានដាក់នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២១)។

[14] ឯកសារ **D270/6** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់ការឆ្លើយតប ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១។

[15] ឯកសារ **D270/7** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ ("សេចក្តីសម្រេចក្នុងការបញ្ជូនរឿងរបស់ ស.ច.ស")។

[16] សារអេឡិចត្រូនិក ពីលោកស្រី Brenda J. Hollis មានចំណងជើងថា "សំណើសុំពន្យារពេលដើម្បីដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ ស្របតាមវិធាន ៨០" ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២១ ម៉ោង ២.០២ រសៀល *ដោយភ្ជាប់ទូវ* "សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំពន្យារពេលកំណត់នៃវិធាន ៨០(១) ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២១ ("សំណើសុំពន្យារពេលវេលារបស់ ស.ព.អ ទៅកាន់ អ.ជ.ស.ដ")។

[17] សារអេឡិចត្រូនិក ពីក្រឡាបញ្ជី អ.ជ.ស.ដ ស៊ុយ ហុងលឹម មានចំណងជើងថា "យោង សំណើសុំពន្យារពេលដើម្បីដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ ស្របតាមវិធាន ៨០" ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ម៉ោង ៧.២៧ យប់។

[18] ឯកសារ **D269/4** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាសម្រេចលើភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ("សេចក្តីពិចារណាលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ.ប.ជ")។

អ.ប.ជ បានបញ្ជាក់អះអាងជាឯកច្ឆន្ទថា នៅក្នុងសេចក្ដីពិចារណាចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១ ខ្លួនបានសម្រេច ក្នុងចំណោមរឿងផ្សេងទៀត ថា (i) ចៅក្រមមិនមានសំឡេងភាគច្រើនគ្រប់គ្រាន់តាមលក្ខខណ្ឌតម្រូវ ដើម្បីធ្វើការសម្រេច "ផ្អែកលើសំអាងហេតុរួម" លើអង្គសេចក្ដីនៃបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយបានទេ[19] (ii) ចៅក្រមជាតិបានរកឃើញថាដីកាដំណោះស្រាយទាំងពីរមានសុពលភាព និងថាសំណុំរឿងប្រឆាំងមាស មុត គួរបានបញ្ជូនទៅរក្សាទុកនៅបណ្ណសារនៃ អ.វ.ត.ក[20] និង (iii) ចៅក្រមអន្តរជាតិបានរកឃើញថា(ក) ដីកាសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ ("ស.ច.ស.ជ") ត្រូវបានចាត់ទុកជាមោឃៈ និងគ្មានសុពលភាព ហើយបានចេញ *ហួសដែលសមត្ថកិច្ច* (ខ) ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") មានសុពលភាព និង (គ) គប្បីបញ្ជូនខ្លួន មាស មុត ទៅជំនុំជម្រះនៅចំពោះមុខ អ.ជ.ស.ដ តាមការអនុវត្តគោលការណ៍នៃការបន្តការចោទប្រកាន់[21]។

## III. ច្បាប់ជាធរមាន

9. ច្បាប់ជាធរមាន ចែងនូវផ្នែកដែលពាក់ព័ន្ធដូចខាងក្រោម។

## IV. សារណា

10. ស.ព.អ សូមដាក់ជូនសំណើនេះ អនុលោមតាមមាត្រា ១២(២) នៃកិច្ចព្រមព្រៀង[22] អ.វ.ត.ក មាត្រា

---

[19] ឯកសារ **D269/4** សេចក្ដីពិចារណាលើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ អ.ប.ជ កថាខណ្ឌ ៣០ (ឯកច្ឆន្ទ)។

[20] ឯកសារ **D269/4** សេចក្ដីពិចារណាលើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ អ.ប.ជ កថាខណ្ឌ ៣០ (ឯកច្ឆន្ទ)។ *សូមមើលផងដែរ* ឯកសារ **D269/4** សេចក្ដីពិចារណាលើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ អ.ប.ជ យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី កថាខណ្ឌ ៤៤ ("ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះយល់ឃើញថា ដីកាដំណោះស្រាយទាំងពីរមានតម្លៃស្មើគ្នា *ត្រូវតម្កល់ទុកជាបានការដូចគ្នា មានសុពលភាពដូចគ្នា* និងថា សំណុំរឿង ០០៣ ប្រឆាំងជនត្រូវចោទ មាស មុត ទៅតម្កល់ទុកនៅបណ្ណសារនៃ អ.វ.ត.ក") (សង្កត់ន័យដើម)។

[21] ឯកសារ **D269/4** សេចក្ដីពិចារណាលើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ អ.ប.ជ កថាខណ្ឌ ៣០ (ឯកច្ឆន្ទ)។

[22] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៤ ("កិច្ចព្រមព្រៀង អ.វ.ត.ក") មាត្រា ១២(២) ("អង្គជំនុំជម្រះវិសាមញ្ញ ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន សមស្របតាមបទដ្ឋានគតិយុត្តិអន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ["ICCPR"] ដែលកម្ពុជា គឺជាភាគីហត្ថលេខីដែរ"), ICCPR, ញូយ៉ក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ១៩៦៦, 999 UNTS 171, មាត្រា១៤(៣)(គ) ("ក្នុងការកំណត់អំពីបទចោទព្រហ្មទណ្ឌណាមួយប្រឆាំងនឹងជនណាម្នាក់

៣៣ និងមាត្រា ៣៥ថ្មី នៃច្បាប់ អ.វ.ត.ក[23] និងវិធាន ២១(១), ២១(៤)[24], ៧៧(១៣), ៧៧(១៤)[25] និង ៧៨[26] នៃវិធានផ្ទៃក្នុងដើម្បីឲ្យស្របនឹងអាណត្តិដែល អ.វ.ត.ក ដឹកនាំអនុវត្តចំណាត់ការរបស់ខ្លួនពាក់ព័ន្ធនឹងសិទ្ធិ និងផលប្រយោជន៍របស់ភាគី*ទាំងអស់* នៃសំណុំរឿង ០០៣ និងដំណើរការច្បាប់ត្រឹមត្រូវ និងស្របជាមួយនឹងគោលការណ៍ជាមូលដ្ឋាននៃភាពប្រាកដប្រជាផ្លូវច្បាប់ ភាពឆាប់រហ័សប្រសិទ្ធិភាព តម្លាភាព ការគ្រប់គ្រងរដ្ឋបាលតុលាការដែលល្អនិងត្រឹមត្រូវយុត្តិធម៌ និងករណីយកិច្ចរបស់ចៅក្រមក្នុងការដោះស្រាយបញ្ហាចំពោះមុខខ្លួន។

11. សម្រាប់មូលហេតុដូចបានបញ្ជាក់យ៉ាងលម្អិតខាងក្រោម សេចក្តីពិចារណារបស់ អ.ប.ជ មានកំហុសផ្នែកច្បាប់ដែលនាំឲ្យមានភាពអយុត្តិធម៌ជាក់ស្តែង ដោយសារការមិនបញ្ជូនសំណុំរឿងទៅ អ.ជ.ស.ដ សម្រាប់ការជំនុំជម្រះស្របនឹងក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក និងសេចក្តីសម្រេចជាឯកច្ឆន្ទរបស់ អ.ប.ជ ដែលថាដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព។ ជាលទ្ធផលបណ្តាលមកពីការមិនចេញសេចក្តីសម្រេចចុងក្រោយមួយដើម្បីអនុវត្តការសម្រេចជាឯកច្ឆន្ទរបស់ខ្លួនឯង ហើយធ្វើការបិទបញ្ចប់

---

ជននោះមានសិទ្ធិទទួលបាននូវការធានាអប្បបរមាដូចតទៅ៖ ស្មើភាពគ្នាទាំងស្រុង [...] (គ) ចំពោះការជំនុំជម្រះដោយគ្មានការពន្យារពេលសមស្រប")។

[23] ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ជាមួយច្បាប់វិសោធនកម្មដែលបានប្រកាសឲ្យប្រើ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ("ច្បាប់ អ.វ.ត.ក") មាត្រា ៣៣ថ្មី ("អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅឲ្យបានត្រឹមត្រូវ និងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ និងមានការការពារឲ្យបានត្រឹមត្រូវចំពោះជនរងគ្រោះ"), មាត្រា ៣៥ថ្មី ("នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បរមា [...] គ. ការជំនុំជម្រះដោយគ្មានការអូសបន្លាយ")។

[24] វិធាន២១ ("គោលការណ៍ជាសារវន្ត។ ១. ច្បាប់ អ.វ.ត.ក វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលជាធរមានត្រូវតែបកស្រាយក្នុងន័យ*ការពារជានិច្ចដល់ផលប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ* និងដើម្បី*ធានាអំពីសច្ចភាពផ្លូវច្បាប់* និងតម្លាភាពនៃកិច្ចដំណើរការនីតិវិធី ដោយគិតដល់លក្ខណៈពិសេសរបស់ អ.វ.ត.ក ដូចមានចែងនៅក្នុងច្បាប់ អ.វ.ត.ក និងកិច្ចព្រមព្រៀង អ.វ.ត.ក។ ក្នុងបរិបទនេះ៖ ១) កិច្ចដំណើរការនីតិវិធី អ.វ.ត.ក ត្រូវតែត្រឹមត្រូវយុត្តិធម៌ និងត្រូវគោរពគោលចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ។ [...] គ) អ.វ.ត.ក ត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានការពារក្នុងអំឡុងពេលទាំងមូលនៃដំណើរការនីតិវិធីរឿងក្តី។ [...] ៤. ការសម្រេចសេចក្តីលើការចោទប្រកាន់ចំពោះមុខ អ.វ.ត.ក ត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប" (សង្កត់ន័យដើម))។

[25] វិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង តម្រូវឲ្យ អ.ប.ជ ផ្តល់សំអាងហេតុ និងចុះហត្ថលេខាលើសេចក្តីសម្រេចរបស់ខ្លួន។

[26] វិធាន ៧៨ នៃវិធានផ្ទៃក្នុង ដោយមានការលើកលែងដ៏មានកម្រិត តម្រូវឲ្យ អ.ប.ជ បោះពុម្ពផ្សាយរាល់សេចក្តីសម្រេចដែលមានសំឡេងគាំទ្រគ្រប់គ្រាន់ និងរាល់សេចក្តីសម្រេចដែលមិនមានសំឡេងគាំទ្រគ្រប់គ្រាន់ទាំងស្រុង។

ដំណាក់កាលមុនការជំនុំជម្រះនៃសំណុំរឿង ០០៣ នោះអង្គជនុំជម្រះបានដាក់ឲ្យកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ជ ស្ថិតក្នុងភាពមិនប្រាកដប្រជាតាមផ្លូវតុលាការជាថ្មីម្តងទៀត។

12. តាមមតិយោបល់រៀង១ខ្លួន ដោយបានឈានដល់សេចក្តីសម្រេចអំពីសុពលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងដីកាសម្រេចលើកលែងចោទប្រកាន់ ចៅក្រម អ.ប.ជ ជាតិនិងអន្តរជាតិ បានបញ្ចេញទស្សនយល់ឃើញពីរដាច់ដោយឡែក លើអ្វីដែលជាការកំណត់ចុងក្រោយដែលគួរតែធ្វើ ក្នុងការបញ្ចប់ដំណាក់កាលមុនជំនុំជម្រះនៃសំណុំរឿង ០០៣៖ ចៅក្រមជាតិបានប្រកាសថា សំណុំរឿងប្រឆាំង មាស មុត គួរត្រូវបានរក្សាទុកនៅក្នុងបណ្ណសារ ហើយចំណែកចៅក្រមអន្តរជាតិបានប្រកាសថា សំណុំរឿង ០០៣ គួរតែត្រូវបានបញ្ជូនទៅជំនុំជម្រះដោយផ្អែកតាមមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ[27]។ គ្មានចំណុចណាមួយនៅក្នុងសេចក្តីពិចារណា ត្រូវបានចៅក្រម អ.ប.ជ ទាំងប្រាំរូបព្រមព្រៀងយកជា *ការកំណត់ជាចុងក្រោយ* ដើម្បីបិទបញ្ចប់ជាស្ថាពរនូវដំណាក់កាលមុនការជំនុំជម្រះលើសំណុំរឿង ០០៣ ដោយការសម្រេចឲ្យមានជំហ៊ានបន្ទាប់ ស្របតាមស្មារតីនៃសេចក្តីសម្រេច*ទាំងអស់* ដែលបានធ្វើឡើងដោយចៅក្រម អ.ប.ជ ឡើយ។ ការខកខានមិនមានជំហានចុងក្រោយនោះ និងការមិនបានផ្តល់ការសម្រេចជាស្ថាពរមួយដែលឯកភាពគ្នា នោះ អ.ប.ជ បានប្រព្រឹត្តកំហុសផ្នែកច្បាប់។

13. ទោះបីជា ស.ព.អ នៅតែប្រកាន់ទស្សនៈរបស់ខ្លួនថា អ.ជ.ស.ជ ត្រូវបានប្តឹងឲ្យទទួលយករឿងក្តី ០០៣ ដោយការអនុវត្តច្បាប់តាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុងយ៉ាងណាក្តី[28] ក៏ ស.ច.ស បានបដិសេធមិនបញ្ជូនសេចក្តីពិចារណា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿងដែលនៅសេសសល់នោះទេ ប្រសិនបើគ្មានសេចសម្រេចមួយដាច់ស្រេចពី អ.ប.ជ[29]។ បើមិនមានសំណុំរឿងទេ អ.ជ.ស.ជ បដិសេធមិនបំពេញកិច្ចក្នុងរឿងក្តី ០០៣[30] ដូចគ្នាដែលខ្លួនបានធ្វើក្នុងរឿងក្តី ០០៤/២ ដែរ[31]។ បរាជ័យរបស់ អ.ប.ជ ឬការបដិសេធមិនចេញសេចក្តីសម្រេចជាស្ថាពរមួយដែលឯកភាពគ្នា ក្នុងការបិទបញ្ចប់

[27] *សូមមើលយោងខាងលើ* កថាខណ្ឌ៥, ៨។

[28] ឯកសារ **D270** សំណើររបស់ ស.ព.អ ទៅកាន់ ស.ច.ស កថាខណ្ឌ ១២-១៣។ សំណើសុំពន្យារពេលរបស់ ស.ព.អ ទៅកាន់ អ.ប.ជ កថាខណ្ឌ៩-១០។

[29] ឯកសារ **D270/7** សេចក្តីសម្រេចរបស់ ស.ច.ស ស្តីពីការបញ្ជូន កថាខណ្ឌ ២៥, ៣៨-៣៩ ផ្នែកសម្រេចសេចក្តី ត្រង់ EN 01671507, FR 01672328, KH 01671536។

[30] *សូមមើល យោងខាងលើ* កថាខណ្ឌ ៧។

[31] ឯកសារ **D267/29.1.12** សេចក្តីថ្លែងការរបស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ទាក់ទងនឹង សំណុំរឿង ០០៤/២ ដែលពាក់ព័ន្ធនឹង អោ អាន ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០។

ដំណាក់ការមុនការជំនុំជម្រះរឿងក្តី ០០៣ ជាថ្មីម្តងទៀតបានបង្កើតនូវភាពជាប់គាំងផ្នែកតុលាការ ដែលធ្វើឱ្យមានអពលានុភាពនៃប្រព័ន្ធតុលាការ អ.វ.ត.ក។

14. ភាគី *ទាំងអស់* នៃរឿងក្តី ០០៣ មានសិទ្ធិទទួលបាននូវដំណោះស្រាយ *តាមផ្លូវតុលាការ* ទាន់ពេលវេលា និងយុត្តិធម៌លើបណ្តឹងឧទ្ធរណ៍មុនពេលជំនុំជម្រះដែលនាំមកនូវសច្ចភាពនិងភាពប្រកដប្រជាផ្នែកច្បាប់ ចំពោះបញ្ហាថាតើរឿងក្តី ០០៣ នឹងបន្តទៅជំនុំជម្រះ ឬយ៉ាងណា និងផ្អែកលើមូលដ្ឋានអ្វីខ្លះ។ ដូចដែលអង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") បានបញ្ជាក់ច្បាស់នៅក្នុងរឿងក្តី ០០៤/២ រយៈពេលស្ទើរតែប្រាំបីខែមុនការចេញសេចក្តីពិចារណាក្នុងរឿងក្តី ០០៣[32] និងដូចដែល អ.ប.ជ បានទទួលស្គាល់ដោយខ្លួនឯងផ្ទាល់[33] នៅពេលចេញសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ វាគឺជាតួនាទីរបស់ចៅក្រម អ.ប.ជ ក្នុងការធានាថា ដំណាក់កាលមុនការជំនុំជម្រះនៃរឿងក្តី ០០៣ ត្រូវបានចាត់ការតាមវិធីមួយដែលនាំមកនូវសច្ចភាព និងភាពប្រាកដប្រជាផ្នែកច្បាប់ និងដែលលុបបំបាត់ភាពមិនច្បាស់លាស់តាមផ្លូវតុលាការ។ និយាយម្យ៉ាងទៀត អ.ប.ជ មានកាតព្វកិច្ចត្រូវចេញសេចក្តីសម្រេចមួយជាស្ថាពរ[34] អនុលោមតាមវិធាន ៧៨ នៃវិធានផ្ទៃក្នុង រួមបញ្ចូលទាំងការបញ្ជាក់យ៉ាងច្បាស់ លើសេចក្តីសម្រេច និងសេចក្តីសម្រេចដែលមិនមានសំឡេងគាំទ្រគ្រប់គ្រាន់របស់ខ្លួនទាំងអស់[35]។ ចំណុចនេះស្របទៅនឹងលក្ខខណ្ឌតម្រូវនៃវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង ដែលចែងថា រាល់សេចក្តីសម្រេចរបស់

---

[32] សំណុំរឿង ០០៤/២-ឯកសារ **E004/2/1/1/2** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/០២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ("សេចក្តីសម្រេចរបស់ អ.ជ.ត.ក") កថាខណ្ឌ ៥៩-៦១, ៦៨, ៧១ (គឺ អ.ប.ជ ដែលជាអ្នកនាំមកនូវដំណោះស្រាយស្ថាពរចំពោះរឿងក្តីនានានៅចំពោះមុខខ្លួន)។

[33] ឯកសារ **D266/24 & D267/32** សេចក្តីសម្រេចលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺលើសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងរឿងក្តី០០៤/២ ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២០ កថាខណ្ឌ ៣១។ សំណុំរឿង ០០៤/២-**D359/24 & D360/33** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ("សំណុំរឿង ០០៤/២ សេចក្តីពិចារណា") កថាខណ្ឌ ៤៦, ៥១, ៥៤, ៦៨។

[34] សំណុំរឿង ០០៤/២-**E004/2/1/1/2** សេចក្តីសម្រេច អ.ជ.ត.ក កថាខណ្ឌ ៦១, ៧១។

[35] វិធាន៧៨ ("ការបោះពុម្ពផ្សាយសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ៖ រាល់សេចក្តីសម្រេចដែលមានសំឡេងគាំទ្រគ្រប់គ្រាន់ និង រាល់សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្រគ្រប់គ្រាន់របស់អង្គបុរេជំនុំជម្រះ រួមទាំងមតិជំទាស់ផង *ត្រូវបោះពុម្ពផ្សាយទាំងស្រុង* លើកលែងតែអង្គបុរេជំនុំជម្រះសម្រេចថា ការបោះពុម្ពផ្សាយនោះអាចប៉ះពាល់ដល់ផលប្រយោជន៍នៃការអង្កេតបឋម ឬ ការស៊ើបសួរ"។ (គូសបញ្ជាក់បន្ថែម))

អ.ប.ជ ទាំងអស់ត្រូវមានសំអាងហេតុ[36]។ ហេតុដូច្នេះ ការបរាជ័យក្នុងការចេញសេចក្ដីសម្រេចមួយជាស្ថាពរដែលឯកភាពគ្នា គឺជាកំហុសអង្គច្បាប់ ដែលជាហានិភ័យអាចធ្វើឲ្យជោគវាសនារឿងក្ដី ០០៣ ត្រូវស្ថិតក្នុងភាពមិនច្បាស់លាស់ជារៀងរហូតដោយអសកម្មភាពផ្នែកតុលាការ ឬ ត្រូវបង្វែរកាតព្វកិច្ចនេះទៅ អ.ជ.ស.ដ ឬ អ.ជ.ត.ក វិញ ក្នុងការបិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីទាំងនេះ ដើម្បីរារាំងអពលានុភាពផ្នែកស្ថាប័នដែលបានដាក់តាមផ្លូវតុលាការនេះ។

15. អ.ជ.ស.ដ បានបញ្ជាក់ពីឋានៈរបស់ខ្លួនផ្ទាល់ថា ជាអង្គជំនុំជម្រះសាលាឧទ្ធរណ៍ដែលមាន "យុត្តាធិការតែមួយ និងជាចុងក្រោយលើបញ្ហានានាមុនការជំនុំជម្រះ"[37] និងមានសិទ្ធិអំណាចច្រើនលើដំណាក់កាលស៊ើបអង្កេត[38]។ អ.ប.ជ បានរំលឹកជាឯកច្ឆន្ទថា គោលបំណងមួយក្នុងចំណោមគោលបំណងសំខាន់ៗ

---

[36] វិធាន ៧៧(១៤)។ *សូមមើលបន្ថែមទៀត ឧទាហរណ៍* សំណុំរឿង ០០២-**D55/I/8** សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ កថាខណ្ឌ ២១ (និងយុត្តិសាស្ត្រខាងក្នុងនោះ) ("អង្គបុរេជំនុំជម្រះយល់ឃើញថា សេចក្ដីសម្រេចទាំងអស់របស់តុលាការតម្រូវឲ្យផ្ដល់សំអាងហេតុ ដោយសារវាជាបទដ្ឋានអន្តរជាតិ")។ សំណុំរឿង០០១-**D99/3/42** សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ កថាខណ្ឌ ៣៨។ សំណុំរឿង ០០២-**E176/2/1/4** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឲ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ("សេចក្ដីសម្រេចតាមវិធាន ៣៥ របស់ អ.ជ.ត.ក") កថាខណ្ឌ ២៥ ("រាល់សេចក្ដីសម្រេចតាមផ្លូវតុលាការទាំងអស់ មិនថា ជាសេចក្ដីសម្រេចផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរឡើយ ត្រូវតែប្រកាន់ខ្ជាប់នូវកាតព្វកិច្ចរបស់តុលាការក្នុងការផ្ដល់សំអាងហេតុគ្រប់គ្រាន់")។ *Milutinović*, IT-99-37-AR65.3, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សេចក្ដីសម្រេចបដិសេធសំណើសុំប្ដឹងឧទ្ធរណ៍របស់ Milutinović ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ ២២ ("ជាផ្នែកមួយនៃការធានានូវការជំនុំជម្រះដោយត្រឹមត្រូវ អង្គជំនុំជម្រះត្រូវតែផ្ដល់យោបល់មានសំអាងហេតុ។ លក្ខខណ្ឌតម្រូវនេះតម្រូវឲ្យអង្គជំនុំជម្រះ ក្នុងចំណោមរឿងផ្សេងទៀត បញ្ជាក់ពីទស្សនៈរបស់ខ្លួនអំពី [...] កត្តាពាក់ព័ន្ធទាំងអស់នោះដែលអង្គជំនុំជម្រះសាលាដំបូងដ៏មានហេតុផល អាចត្រូវបានរំពឹងទុកឲ្យពិចារណាមុនពេលធ្វើសេចក្ដីសម្រេចមួយ")។

[37] ឯកសារ **D266/25** សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់សារណាបន្ថែមលើបណ្ដឹងឧទ្ធរណ៍របស់ខ្លួនជំទាស់ទៅនឹងដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២០ កថាខណ្ឌ ៣១ យោង វិធាន ៧៣, ៧៦(៤), ៧៧(១៣), ៧២(៤)(ឃ)។ សំណុំរឿង០០៤/២-**D359/24** & **D360/33** សំណុំរឿង ០០៤/២ សេចក្ដីពិចារណា កថាខណ្ឌ ៣៥, ៤១ ("[អ.ប.ជ] បច្ចុប្បន្ននេះជាយុត្តាធិការចុងក្រោយបង្អស់នៅដំណាក់កាលបុរេជំនុំជម្រះនៅ អ.វ.ត.ក") ៤៩។

[38] សំណុំរឿង០០៤/២-**D359/24** & **D360/33** សំណុំរឿង ០០៤/២ សេចក្ដីពិចារណា កថាខណ្ឌ ៣០-៥៤ ជាពិសេស កថាខណ្ឌ ៣០, ៣២-៣៣, ៤០-៤៩, ៥១-៥២, ៥៤។ *សូមមើលផងដែរ* សំណុំរឿង០០៤/២-**E004/2/1/1/2** សេចក្ដីសម្រេច អ.ជ.ត.ក កថាខណ្ឌ ៦០-៦១។

របស់ អ.ប.ជ គឺត្រូវវាយតម្លៃភាពជារួមនៃដំណាក់កាលស៊ើបអង្កេត និងត្រូវចេញសេចក្តីសម្រេចស្តាពរទាក់ទងនឹងបញ្ហានេះ[39] និងថា ខ្លួនត្រូវតែធានាថា គោលការណ៍ជាសារវន្តដែលជាមូលដ្ឋាននៃនីតិវិធីព្រហ្មទណ្ឌជាធរមានចំពោះមុខ អ.វ.ត.ក ត្រូវបានគោរព[40]។ គោលការណ៍មួយដែលបានលើកឡើងដោយអង្គជំនុំជម្រះនេះ គឺមាន "ភារកិច្ចតាមផ្លូវតុលាការក្នុងការប្រកាស ដោយផ្អែកទៅលើច្បាប់សេចក្តីសម្រេចលើបញ្ហាដែលមានវិវាទ [...] [ដែល] ជាចំណុចសំខាន់បំផុតនៃការទទួលខុសត្រូវ និងមុខងារដ៏ខ្ពង់ខ្ពស់បំផុតរបស់ចៅក្រម"[41]។ ហេតុដូច្នេះ អ.ប.ជ បានបញ្ជាក់ថា "ចៅក្រមមិនអាចគេចចេញពីការវិនិច្ឆ័យលើបញ្ហាដែលនៅចំពោះមុខខ្លួន ឬគេចចេញពីការធ្វើសេចក្តីសន្និដ្ឋាន ដែលសម្រេចដោយប្រសិទ្ធភាពទៅលើបញ្ហានេះនោះទេ"[42]។ តាមពិតនោះ វាគឺជាកាតព្វកិច្ចតុលាការជាសកលក្នុងការដោះស្រាយបញ្ហាវិវាទ *ទាំងអស់* ទោះបីជាវាស្មុគស្មាញយ៉ាងណាក៏ដោយ និងក្នុងការផ្តល់នូវដំណោះស្រាយផ្លូវច្បាប់ឲ្យទាន់ពេលវេលា និងស្របតាមច្បាប់ជាធរមាន ដូច្នេះ ជៀសផុតពីយុត្តិនិសេធ[43]។

---

[39] សំណុំរឿង០០៤/២-**D359/24 & D360/33** សំណុំរឿង ០០៤/២ សេចក្តីពិចារណា កថាខណ្ឌ ៤៩ (ជាឯកច្ឆន្ទ)។

[40] សំណុំរឿង០០៤/២-**D359/24 & D360/33** សំណុំរឿង ០០៤/២ សេចក្តីពិចារណា កថាខណ្ឌ ៥២ (ជាឯកច្ឆន្ទ)។

[41] សំណុំរឿង០០៤/២-**D359/24 & D360/33** សំណុំរឿង ០០៤/២ សេចក្តីពិចារណា កថាខណ្ឌ ១២២ (ជាឯកច្ឆន្ទ)។ *សូមមើលផងដែរ* ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា កថាខណ្ឌ ១០៥(ជាឯកច្ឆន្ទ)។ សំណុំរឿង ០០៤/២-**E004/2/1/1/2** សេចក្តីសម្រេច អ.ជ.ត.ក កថាខណ្ឌ ៥៩, ៦១។

[42] សំណុំរឿង០០៤/២-**D359/24 & D360/33** សំណុំរឿង ០០៤/២ សេចក្តីពិចារណា កថាខណ្ឌ ១២២ (ជាឯកច្ឆន្ទ)។

[43] សំណុំរឿង ០០៤/២-**E004/2/1/1/2** សេចក្តីសម្រេច អ.ជ.ត.ក កថាខណ្ឌ ៥៩, ៦៤។ គោលការណ៍ជាមូលដ្ឋានរបស់ អ.ស.ប ស្តីពីឯករាជភាពរបស់តុលាការ ដែលបានអនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំពីរ ស្តីពីការទប់ស្កាត់ឧក្រិដ្ឋកម្ម និងការប្រព្រឹត្តលើជនល្មើស ត្រូវបានអនុម័តយល់ព្រមដោយសេចក្តីសម្រេចមហាសន្និបាតលេខ 40/32 ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ ១៩៨៥ មាត្រា ២ ("តុលាការត្រូវសម្រេចលើបញ្ហានៅចំពោះមុខខ្លួន [...] ស្របទៅតាមច្បាប់")។ (គូសបញ្ជាក់បន្ថែម) ក្រមសីលធម៌ចៅក្រម អ.វ.ត.ក ដែលបានកែប្រែនៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨ មាត្រា ៥(៣) ("ចៅក្រមត្រូវបំពេញគ្រប់តួនាទីភារកិច្ចតុលាការឲ្យបានឆាប់រហ័ស និងត្រឹមត្រូវ")។ *In re Desgranges ទល់នឹង អង្គការ ILO*, សាលក្រម No. 11 ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៥៣ (ការមិនអាចអនុញ្ញាតឲ្យសាលាក្តីមួយប្រកាសថា វាមិនច្បាស់ (*non liquet*) ដោយសារតែភាពស្ងៀមស្ងាត់ ឬភាពមិនច្បាស់លាស់នៃច្បាប់នោះ ត្រូវបានចាត់ទុកថាជា "គោលការណ៍គ្រឹះនៃប្រព័ន្ធច្បាប់ទាំងអស់")។ តុលាការយុត្តិធម៌អន្តរជាតិអចិន្ត្រៃយ៍ ("PCIJ") គណៈកម្មាធិការប្រឹក្សាអ្នកច្បាប់ *កំណត់ហេតុ (Procès-Verbaux)* នៃកិច្ចដំណើរការនីតិវិធីរបស់គណៈកម្មាធិការ ចុះថ្ងៃទី១៦ ខែមិថុនា-២៤ កក្កដា ឆ្នាំ១៩២០ (ទីក្រុងឡាអេ ឆ្នាំ១៩២០) ទំព័រ ៣១២ ["វាមិនអាចទៅរួចទេក្នុងការទទួលស្គាល់ការប្រកាសអំពីការមិនអាចធ្វើសេចក្តីសម្រេចបានដោយតុលាការអន្តរជាតិ ការបដិសេធយុត្តិធម៌ត្រូវតែដកចេញពីតុលាការអន្តរជាតិ ដូចគ្នាទៅនឹងការដកចេញពីតុលាការជាតិដែរ"]។ នីត្យានុកូលភាពនៃការគំរាមកំហែង ឬការប្រើប្រាស់អាវុធនុយក្លេអ៊ែ យោបល់ប្រឹក្សា ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៩៩៦ របាយការណ៍ ICJ ឆ្នាំ១៩៩៦ យោបល់ជំទាស់ Higgins កថាខណ្ឌ ៣៨-៣៩។ *សូមមើលផងដែរ ឧទាហរណ៍* **ប្រទេសបារាំង៖** ក្រមរដ្ឋប្បវេណី មាត្រា ៤ ["Le juge qui refusera de juger, sous prétexte du silence, de l'insuffisance ou de l'insufficance de la loi, pourra

ដូចដែល អ.ជ.ត.ក បានពន្យល់នៅក្នុងរឿងក្តី០០២ ថា៖

> ការចាំបាច់ដែលសេចក្តីសម្រេចមួយតាមផ្លូវតុលាការ ត្រូវចាត់ការលើបញ្ហាអង្គច្បាប់មួយដែលស្ថិតនៅចំពោះមុខខ្លួនឲ្យបានច្បាស់លាស់។ ហេតុដូច្នេះ សេចក្តីសម្រេចតាមផ្លូវតុលាការគួរតែប្រើមានផ្នែកមួយ [...] ដែលដោះស្រាយចំពោះអង្គសេចក្តី ហើយ/ឬ *បញ្ហានីតិវិធី* ដោយបង្កើត កែប្រែ បដិសេធចោលឬទទួលយកនូវទំនាក់ទំនងដែលសំអាងខាងលើ ដែលមានជាប់ពាក់ព័ន្ធនឹងភាគីនានា [...] *[រាល់]* សេចក្តីសម្រេចតាមផ្លូវតុលាការទាំងអស់ [...]ត្រូវតែប្រកាន់ខ្ជាប់នូវកាតព្វកិច្ចរបស់តុលាការក្នុងការផ្តល់សំអាងហេតុគ្រប់គ្រាន់[44]។

16. នៅក្នុងសេចក្តីពិចារណារបស់ខ្លួនក្នុងរឿងក្តី ០០៣ អ.ប.ជ បានរកឃើញកំហុសអង្គច្បាប់នៅក្នុង "ការចេញសេចក្តីសម្រេចផ្ទុយគ្នាចំនួនពីរក្នុងពេលដំណាលគ្នា ហើយចេញដោយការិយាល័យតុលាការតែមួយ"[45]។ អង្គជំនុំជម្រះបានសង្កេតឃើញថា សេចក្តីសម្រេចខ្វែងគ្នា ដែលបង្កើតបានជាស្ថានការណ៍ដ៏លំបាកផ្នែកច្បាប់នៅក្នុងកិច្ចដំណើរការនីតិវិធី អ.វ.ត.ក បន្ទាប់ពីការស៊ើបអង្កេតអស់រយៈពេលជាងដប់ឆ្នាំក្នុងឧក្រិដ្ឋកម្មនានា ក្នុងចំណោមឧក្រិដ្ឋកម្មដ៏ឃោរឃៅ និងសាហាវយង់ឃ្នងបំផុត ក្នុងអំឡុងនៃសតវត្សទីម្ភៃ គឺមិនអាចទទួលយកបានទេ៖[46] វាធ្វើឲ្យចុះខ្សោយដល់មូលដ្ឋាននៃប្រព័ន្ធតុលាការកូនកាត់ និងដំណើរការត្រឹមត្រូវរបស់ អ.វ.ត.ក[47] ដែលជាការធ្វើឲ្យខូចដល់ភារកិច្ចដ៏ខ្ពង់ខ្ពស់បំផុតរបស់

être poursuivi comme coupable de déni de justice" បកប្រែក្រៅផ្លូវការ៖ "ចៅក្រមដែលបដិសេធមិនវិនិច្ឆ័យក្រោមហេតុផលនៃភាពស្ងៀមស្ងាត់ ភាពមិនច្បាស់លាស់ ឬភាពមិនគ្រប់គ្រាន់នៃច្បាប់ អាចត្រូវបានកាត់ទោសថា មានពិរុទ្ធពីការបដិសេធយុត្តិធម៌។" **ប្រទេសបែលហ្ស៊ិក៖** ក្រមយុត្តិធម៌ឆ្នាំ ១០ តុលា ១៩៦៧ មាត្រា ៥ ["Il y a déni de justice lorsque le juge refuse de juger sous quelque prétexte que ce soit, même du silence, de l'obscurité ou de l'insuffisance de la loi." បកប្រែក្រៅផ្លូវការ៖ "ការបដិសេធយុត្តិធម៌កើតឡើងនៅពេលដែល ចៅក្រមបដិសេធមិនវិនិច្ឆ័យក្រោមហេតុផលណាមួយ ដូចជា ភាពស្ងៀមស្ងាត់ ភាពមិនច្បាស់លាស់ ឬភាពមិនគ្រប់គ្រាន់នៃច្បាប់"។

44 សំណុំរឿង ០០២-E176/2/1/4 សេចក្តីសម្រេចតាមវិធាន ៣៥ របស់ អ.ជ.ត.ក កថាខណ្ឌ ២៥ (គូសបញ្ជាក់បន្ថែម) និងការយោងសំអាងខាងក្នុងនោះ)។

45 ឯកសារ **D266/27** & **D267/35** សេចក្តីពិចារណា កថាខណ្ឌ ១០៦-១០៩ (ជាឯកច្ឆន្ទ) (ដកស្រង់ត្រង់កថាខណ្ឌ ១០៩)។ សំណុំរឿង ០០៤/២-**D359/24** & **D360/33** សំណុំរឿង ០០៤/២ សេចក្តីពិចារណា កថាខណ្ឌ ១២៤ (ជាឯកច្ឆន្ទ)។

46 ឯកសារ **D266/27** & **D267/35** សេចក្តីពិចារណា កថាខណ្ឌ ១០៩ (ជាឯកច្ឆន្ទ)។ សំណុំរឿង ០០៤/២-**D359/24** & **D360/33** សេចក្តីពិចារណា កថាខណ្ឌ ៨៩, ១២៤ (ជាឯកច្ឆន្ទ)។

47 ឯកសារ **D266/27** & **D267/35** សេចក្តីពិចារណា កថាខណ្ឌ ១០៦ (ជាឯកច្ឆន្ទ)។

ចៅក្រម[48] និងជាយុត្តិនិសេធ[49]។ អ.ប.ជ សង្កត់ធ្ងន់ថា ពេលដែលការខ្វែងយោបល់គ្នាក្នុងការិយាល័យតុលាការ អ.វ.ត.ក រារាំងចៅក្រមពីការឈានទៅដល់ការសម្រេចជាស្ថាពរជារួមមួយនោះ ពួកគេនៅតែត្រូវបំពេញភារកិច្ចតុលាការរបស់ខ្លួន ដោយការអនុវត្តតាមនីតិវិធីដែលមាននៅក្នុងប្រព័ន្ធច្បាប់ អ.វ.ត.ក ដើម្បីធ្វើឱ្យប្រាកដថា ការសម្រេចដាច់ស្រេចមួយលើបញ្ហានានានៅក្នុងយុត្តាធិការរបស់ខ្លួនអាចធ្វើទៅបាន[50]។

17. តាមរយៈការចេញយោបល់ពីរដាច់ដោយឡែកពីគ្នា លើអ្វីដែលគួរតែជាសេចក្តីសម្រេចជាស្ថាពរបិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃរឿងក្តី ០០៣ ជាជាងការចេញសេចក្តីសម្រេចមួយជាស្ថាពរច្បាស់លាស់ អ.ប.ជ ខកខានមិនបានបំពេញភារកិច្ចតុលាការដែលខ្លួនបានលើកឡើងជាឯកច្ឆន្ទ បានបង្កើតកំហុសអង្គច្បាប់ និងបណ្តាលឱ្យមានភាពអយុត្តិធម៌ជាក់ស្តែង។

*អ.ប.ជ ត្រូវបញ្ជូនរឿងក្តី ០០៣ ទៅជំនុំជម្រះ ក្រោយពីសេចក្តីសម្រេចជាឯកច្ឆន្ទរបស់ខ្លួនថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព*

18. នៅក្នុងសេចក្តីពិចារណានោះ ចៅក្រមទាំងប្រាំរូបនៃ អ.ប.ជ បានសន្និដ្ឋានថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព[51] ដែលបង្កើតបានជាសេចក្តីសម្រេចមួយមានសំឡេងភាគច្រើនលើសលុបតាមអត្ថន័យនៃវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង ដែលបិទផ្លូវប្តឹងឧទ្ធរណ៍។ វិធាន ៧៧(១៣) បញ្ជាក់ច្បាស់ថា៖ "សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ តម្រូវឱ្យមានសំឡេងគាំទ្រជាវិជ្ជមានពីចៅក្រម៤ (បួន)រូបយ៉ាងតិច"[52]។ ការណ៍ដែលថា ចៅក្រម អ.ប.ជ ទាំងប្រាំរូបបានផ្តល់នូវសំអាងហេតុផ្សេងគ្នាចំពោះសេចក្តីសន្និដ្ឋានផ្នែកច្បាប់ដែលថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព ដូច្នេះបានរំពុក

[48] សំណុំរឿង ០០៤/២-**D359/24** & **D360/33** សំណុំរឿង ០០៤/២ សេចក្តីពិចារណា កថាខណ្ឌ ៨៩ (ជាឯកច្ឆន្ទ)។ *សូមមើលផងដែរ* ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា កថាខណ្ឌ ១០៥ (ជាឯកច្ឆន្ទ)។

[49] ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា កថាខណ្ឌ ១០៨ (ជាឯកច្ឆន្ទ)។ សំណុំរឿង ០០៤/២-**D359/24** & **D360/33** សំណុំរឿង ០០៤/២ សេចក្តីពិចារណា កថាខណ្ឌ ១២៣ (ជាឯកច្ឆន្ទ)។

[50] ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា កថាខណ្ឌ ១០៥ (ជាឯកច្ឆន្ទ)។ សំណុំរឿង ០០៤/២-**D359/24** & **D360/33** សំណុំរឿង ០០៤/២ សេចក្តីពិចារណា កថាខណ្ឌ ១២២ (ជាឯកច្ឆន្ទ)។

[51] *សូមមើលយោងខាងលើ* កថាខណ្ឌ ៤-៥, ៨។

[52] វិធាន ៧៧ (១៣)។

ឡើងវិញនូវសេចក្តីសន្និដ្ឋានជាឯកច្ឆន្ទនោះនៅក្នុងកថាខណ្ឌផ្សេងៗគ្នាក្នុងសេចក្តីពិចារណា[53] មិនបានធ្វើឲ្យថមថយដល់ភាពជាឯកច្ឆន្ទនៃសេចក្តីសម្រេចនោះឡើយ។ តាមពិត នៅក្នុងផ្នែកសម្រេចសេចក្តី អ.ប.ជ បានបញ្ជាក់ជាឯកច្ឆន្ទថា ខ្លួនមិនអាចចេញសេចក្តីសម្រេចមួយ *ដោយផ្អែកលើសំអាងហេតុរួម*បាន[54] គឺមិនមានន័យថា ចៅក្រមទាំងអស់មិនបានឈានដល់ការព្រមព្រៀងជារួមមួយចំពោះសេចក្តីសម្រេចចុងក្រោយនោះឡើយ។ វានឹងផ្ទុយទៅនឹងច្បាប់ ភាពសមហេតុផល និងយុត្តិធម៌ ក្នុងការមើលរំលងការសន្និដ្ឋានជាក់លាក់របស់ចៅក្រមទាំងប្រាំរូបថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព។

19. ការអនុវត្តនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិសម័យទំនើបទាំងអស់ បង្ហាញថា សំអាងហេតុរួម មិនមែនជាលក្ខខណ្ឌតម្រូវជាមុនសម្រាប់សេចក្តីសម្រេចរួមឡើយ។ តាមពិត ក្របខណ្ឌច្បាប់ អ.វ.ត.ក បានគ្រោងទុកយ៉ាងច្បាស់លាស់នូវយោបល់ដាច់ដោយឡែក នៅក្នុងសេចក្តីសម្រេចតុលាការ[55] ហើយអង្គជំនុំជម្រះសាលាឧទ្ធរណ៍ទាំងអស់ក្នុងតុលាការអន្តរជាតិសម័យទំនើប[56] ក៏ដូចជាតុលាការក្រោយ

---

[53] ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា យោបល់របស់ចៅក្រមជាតិ កថាខណ្ឌ ១១៥។ យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ១១៩, ២៦២, ២៨៤ ផ្នែកសម្រេចសេចក្តី ត្រង់ EN 01667089, FR 01667264, KH 01667480។

[54] ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា ផ្នែកសម្រេចសេចក្តីត្រង់ EN 01666984, FR 01667141, KH 01667329 ("[អ.ប.ជ] យោងតាមសម្លេងឯកច្ឆន្ទ [...] ប្រកាសថា អង្គបុរេជំនុំជម្រះមិនអាចរកសំឡេងគាំទ្រពីចៅក្រម ៤ (បួន) រូប យ៉ាងតិច ដើម្បីចេញសេចក្តីសម្រេចមួយទៅលើអង្គសេចក្តី ដោយផ្អែកលើសំអាងហេតុរួមមួយបានឡើយ។") *សូមមើលផងដែរ* កថាខណ្ឌ ១១០។

[55] វិធាន ១០១ (២), ១១១(១) (ទាក់ទំនឹងសាលក្រម និងសាលដីកា៖ "ប្រសិនបើមិនមានសម្លេងជាឯកច្ឆន្ទទេ [លើសំអាងហេតុផ្នែកអង្គហេតុ ឬផ្នែកច្បាប់] ចៅក្រមអាចសរសេរយោបល់ដោយឡែកមួយផ្សេង ឬ យោបល់ជំទាស់នៅក្នុងករណីនេះ ហើយត្រូវភ្ជាប់ទៅនឹងសាលក្រម")។ កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា៤(២) ("នៅពេលដែលគ្មានការឯកភាពជាឯកច្ឆន្ទទេ ការសម្រេចសេចក្តីរបស់អង្គជំនុំជម្រះ ត្រូវមានទស្សនៈរបស់មតិ ភាគច្រើន និងមតិភាគតិច")។ ច្បាប់ អ.វ.ត.ក មាត្រា ១៤(២)។

[56] *សូមមើល ឧទាហរណ៍* **ICTY:** *Krnojelac,* IT-97-25-A, អង្គជំនុំជម្រះតុលាការកំពូល សាលដីកា ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៣ យោបល់ដោយឡែករបស់ចៅក្រម Schomburg (ឯកភាពជាមួយការសន្និដ្ឋានដែលធ្វើឡើងដោយអង្គជំនុំជម្រះតុលាការកំពូល ប៉ុន្តែមិនឯកភាពជាមួយនឹងសំអាងហេតុជាក់លាក់មួយចំនួន ដែលផ្តល់នៅក្នុងសាលដីកាទេ។)។ *Kupreškić និងគូកន.*, IT-95-16, អង្គជំនុំជម្រះតុលាការកំពូល យោបល់ដោយឡែករបស់ចៅក្រម David Hunt លើបណ្តឹងសាទុក្ខរបស់ Dragan Papić ប្រឆាំងនឹងសេចក្តីសម្រេចឲ្យបន្តដោយផ្នែកសម្រេចសេចក្តី ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ ២ ("ខ្ញុំឯកភាពជាមួយនឹងសេចក្តីសម្រេចរួមត្រង់ថា បណ្តឹងសាទុក្ខគួរអនុញ្ញាត [...] ប៉ុន្តែខ្ញុំសោកស្តាយដែលថា ខ្ញុំមិនអាចឯកភាពជាមួយនឹងសំអាងហេតុទាំងអស់ដែលផ្តល់ជូននៅក្នុងសេចក្តីសម្រេចរួមសម្រាប់លទ្ធលនោះបានទេ។
ពេលនេះខ្ញុំសូមផ្តល់សំអាងហេតុផ្ទាល់ខ្លួនរបស់ខ្ញុំ ផ្អែកលើបញ្ហាដែលបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខ")។ *Tadić*, IT-94-1, អង្គជំនុំជម្រះតុលាការកំពូល យោបល់ដោយឡែករបស់ចៅក្រម Abi-Saab លើញត្តិរបស់មេធាវីការពារក្តីសម្រាប់បណ្តឹងសាទុក្ខបន្ទាន់បង្ខំលើយុត្តាធិការ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ១៩៩៥ កថាខណ្ឌ ១ ("ខ្ញុំមានការលំបាកខ្លះក្នុងឯកភាពជាមួយរាល់

សង្គ្រាមលោកលើកទីពី[57] បានចេញសេចក្តីសម្រេច និងសាលក្រមដែលមានយោបល់ដាច់ដោយឡែក (យោបល់ស្រប)។

20. ស.ព.អ សូមជំទាស់ទៅនឹងសេចក្តីថ្លែងការណ៍របស់ប្រធាន អ.ប.ជ ក្នុងសំណុំរឿង ០០៤/២ ដែលថា "មានតែផ្នែកនៃផ្នែកសម្រេចសេចក្តីរួមគ្នា ដែលបានសម្រេចជាឯកច្ឆន្ទ និងចុះហត្ថលេខាដោយចៅក្រមទាំងប្រាំរូបប៉ុណ្ណោះមានអានុភាពជាធរមាន"[58]។ តាមពិតនោះ អង្គជំនុំជម្រះនេះជាញឹកញាប់បានធ្វើ

---

សំអាងហេតុទាំងអស់នៃសេចក្តីសម្រេចទាក់ទងនឹងមូលដ្ឋានទី ៣ [...] ទោះជាយ៉ាងណាខ្ញុំដឹងថា ភាពខ្វែងគ្នាទាំងនេះទាក់ទងនឹងដំណើរការនៃសំអាងហេតុផ្លូវច្បាប់ ដែលនាំឱ្យមានលទ្ធផល ជាជាងលទ្ធផលខ្លួនវាផ្ទាល់ ដែលខ្ញុំទទួលស្គាល់ ដែលជាប្រភេទនៃលក្ខណៈ "ដោយឡែក" នៃយោបល់នេះ")។ **ICTR:** *Kanyabashi*, ICTR-96-15-A, សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីសម្រាប់បណ្តឹងសាទុក្ខបន្ទាន់បន្ទំលើយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង I យោបល់ដោយឡែក និងយោបល់ស្របរួមគ្នារបស់ចៅក្រម Wang Tieya និង ចៅក្រម Rafael Nieto-Navia, ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០០៩ កថាខណ្ឌ ១។ *Ngeze & Nahimana,* ICTR-99-52-A, អង្គជំនុំជម្រះតុលាការកំពូល សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បន្ទំ យោបល់ដោយឡែករបស់ចៅក្រម Shahabuddeen ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០០ កថាខណ្ឌ ១ ("ខ្ញុំសូមឯកភាពជាមួយនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ប៉ុន្តែស្នើសុំបញ្ចេញមតិខ្លះលើចំណុចដែលមានមតិយោបល់ខុសគ្នា។ ភាពខុសគ្នានេះមិនប៉ះពាល់ដល់លទ្ធផលនៃរឿងក្តីទេ")។ **SCSL:** *Brima និងគូកន*, SCSL-2004-16-AR73, អង្គជំនុំជម្រះតុលាការកំពូល យោបល់ដោយឡែក និងយោបល់ស្របរបស់ចៅក្រម Robertson លើសេចក្តីសម្រេចលើញត្តិបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី Brima-Kamara ប្រឆាំងនឹងសេចក្តីសម្រេចដោយសំឡេងភាគច្រើននៃអង្គជំនុំជម្រះ II លើញត្តិរួមគ្នាសម្ងាត់បន្ទាន់បំផុត ស្នើសុំឱ្យតែងតាំង Kevin Metzger និង Wilbert Harris ឡើងវិញជាមេធាវីនាំមុខសម្រាប់ Alex Tamba Brima និង Brima Bazzy Kamara ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៥ កថាខណ្ឌ ១។ *សូមមើលបន្ថែមទៀត ឧទា.* លក្ខន្តិកៈដែលបានធ្វើបច្ចុប្បន្នភាពរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ខែកញ្ញា ឆ្នាំ២០០៩ មាត្រា ២៣(២)។ លក្ខខន្តិកៈសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតរ្វាន់ដា ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១០ មាត្រា ២២(២)។ លក្ខន្តិកៈរបស់យន្តការសេសសល់អន្តរជាតិសម្រាប់សាលាក្តីព្រហ្មទណ្ឌ S/RES/1966 (២០១០), ឧបសម្ពន្ធ ១ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០ មាត្រា ២១(២)។ លក្ខន្តិកៈរបស់តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាលេអូន ភ្ជាប់ជាឧបសម្ពន្ធទៅនឹងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលសៀរ៉ាលេអូន ស្តីពីការបង្កើតតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាលេអូន ទីក្រុង Freetown ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០២ 2178 UNTS 137 មាត្រា ១៨។ លក្ខន្តិកៈរបស់សាលាក្តីពិសេសសម្រាប់ប្រទេសលីបង់ S/RES/1757 (២០០៧) ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧ មាត្រា ២៣ (ចែងសម្រាប់យោបល់ដោយឡែកថាត្រូវភ្ជាប់បន្ថែមទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះ)។

[57] *សូមមើល ឧទាហរណ៍ សហរដ្ឋអាមេរិក និង គូកន ទល់នឹង Araki និងគូកន* សាលក្រម ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៤៨ យោបល់ស្របរបស់ចៅក្រម Justice Delfin Jaranilla។ សមាជិកមកពីសាធារណៈរដ្ឋហ្វីលីពីន ទំព័រ១, ៣៥។

[58] សំណុំរឿង ០០៤/២-**D359/34** & **D360/43** អនុស្សរណៈរបស់ប្រធាន អ.ប.ជ ទាក់ទងនឹងសេចក្តីជូនដំណឹងនៃសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ("អនុស្សរណៈថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ របស់ប្រធាន អ.ប.ជ") EN 01640437។ *សូមមើលផងដែរ* ឯកសារ **D266/20.1.11** & **D267/25.1.11** សំណុំរឿង

សេចក្តីសម្រេចដាច់ខាតរបស់ខ្លួន (រួមទាំងសេចក្តីសម្រេចមិនមានសំឡេងគាំទ្រលើសលុប)[59] នៅក្រៅទាំងស្រុងនៃដែនកំណត់នៃផ្នែកសម្រេចសេចក្តីជាឯកច្ឆន្ទ[60]។ ឧទាហរណ៍ នៅក្នុងសេចក្តីពិចារណារបស់ខ្លួនទាក់ ទងនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា លើបញ្ហាថាតើត្រូវប្តឹងទៅ ស.ច.ស នូវសំណុំរឿង ០០៣ និង ០០៤ ឬអត់នោះ ការសន្និដ្ឋានរបស់ អ.ប.ជ ដែលថាដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរគួរត្រូវបញ្ជូនទៅ ស.ច.ស មិនមាននៅក្នុងផ្នែកសម្រេចសេចក្តីទេ[61]។ ការលើកឡើង

---

០០៤/២-អនុស្សរណៈពីប្រធាន អ.ប.ជ ប្រាក់ គឹមសាន មានចំណងជើងថា "ការបញ្ជាក់ឡើងវិញអំពីសេចក្តីសម្រេចលើសំណុំរឿង ០០៤/២" ថ្ងៃទី១៦ មីនា ឆ្នាំ២០២០ ("អនុស្សរណៈថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ របស់ប្រធាន អ.ប.ជ") កថាខណ្ឌ២-៣។

[59] វិធាន ៧៨។

[60] *សូមមើល ឧទាហរណ៍* ឯកសារ **C2/4** សេចក្តីពិចារណាលើសំណើបន្ទាន់របស់ មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ កថាខណ្ឌ ១១-១២, ផ្នែកសម្រេចសេចក្តី។ ឯកសារ **D20/4/4** សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ជំទាស់នឹង សេចក្តីសម្រេចស្តីពីសំណើសុំពន្យាពេលកំណត់ នឹងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១១ ("សេចក្តីពិចារណារបស់ អ.ប.ជ ស្តីពីសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ") កថាខណ្ឌ ១៣-១៤, ផ្នែកសម្រេចសេចក្តី។ ឯកសារ **D11/2/4/4** សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍ ស្តីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីលោក រ៉ូប៊ឺត ហាមីល (Robert Hamill) ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១១ កថាខណ្ឌ ១២-១៣, ផ្នែកសម្រេចសេចក្តី។ សំណុំរឿង០០៤-**D203/1/1/2** ការពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេចទាក់ទងនឹងសំណើរបស់គាត់សុំការបំភ្លឺថា គាត់អាចស៊ើបសួរដោយខ្លួនឯងបាន ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៥ កថាខណ្ឌ ៣០-៣១, ផ្នែកសម្រេចសេចក្តី។

[61] ឯកសារ **D1/1.3** ការពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ("ការពិចារណារបស់ អ.ប.ជ លើករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា") កថាខណ្ឌ ៤៥ (ដូចដែលបានកែតម្រូវនៅក្នុងឯកសារ **D1/1.2** ការកែតម្រូវលើសេចក្តីដកស្រង់ការពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៧១នៃវិធានផ្ទៃក្នុង និង ឧបសម្ព័ន្ធ II ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩) ("កែតម្រូវ") ("ដោយហេតុថា អង្គបុរេជំនុំជម្រះមិនបានឈានដល់សេចក្តីសម្រេចមួយលើការខ្វែងយោបល់គ្នាដែលបានប្តឹងមកខ្លួន វិធាន១៧(៤)(គ) នៃវិធានផ្ទៃក្នុងចែងថា សកម្មភាពរបស់សហព្រះរាជអាជ្ញាអន្តរជាតិត្រូវអនុវត្ត។ ក្នុងរឿងក្តីបច្ចុប្បន្ន ការណ៍នេះមានន័យថា អនុលោមតាវិធាន ៥៣(១) សហព្រះរាជអាជ្ញាអន្តរជាតិត្រូវបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មី ទៅកាន់សហចៅក្រមស៊ើបអង្កេត ដើម្បីបើកការស៊ើបសួរ" ផ្នែកសម្រេចសេចក្តី ត្រង់ EN 00620551, FR 01616997, KH 00620604 ("ហេតុដូច្នេះ អង្គបុរេជំនុំជម្រះ៖ ១) ប្រកាសថាការខ្វែងយោបល់គ្នានេះអាចទទួលយកបាន។ ២) ប្រកាសថា អង្គបុរេជំនុំជម្រះមិនអាចរកបានសំឡេងគាំទ្រយ៉ាងហោចណាស់ចៅក្រមបួនរូបដើម្បីចេញសេចក្តីសម្រេចមួយលើករណីខ្វែងយោបល់គ្នានេះទេ")។

ជាអនុសាធ្យថា មតិយោបល់ដែលបន្ថែមខាងក្រោយរបស់ចៅក្រមមិនមានអានុភាពផ្លូវច្បាប់នោះ[62] ក៏ជាកំហុសស្រដៀងគ្នាដែរ។ ប្រសិនបើពួកវាមិនមានអានុភាពផ្លូវច្បាប់ទេនោះ អង្គជំនុំជម្រះនេះបាន បរាជ័យក្នុងភារកិច្ចរបស់ខ្លួនតាមវិធាន ៧៧(១៤) ក្នុងការផ្ដល់សំអាងហេតុសម្រាប់សេចក្ដីសម្រេច របស់ខ្លួនក្នុងសេចក្ដីពិចារណានេះ និងសេចក្ដីពិចារណាផ្សេងទៀតនៅក្នុងជីវិតនៃ អ.វ.ត.ក ទាំងមូល វាជាបញ្ហាដែល អ.ប.ជ ជាញឹកញាប់ បានទទួលស្គាល់យ៉ាងជាក់លាក់[63] រួមទាំងនៅក្នុងសេចក្ដី ពិចារណាទាំងអស់នេះនៃរឿងក្ដី ០០៣[64]។ ទោះក្នុងករណីណាក៏ដោយ ចៅក្រមទាំងប្រាំរូបបានចុះ ហត្ថលេខាលើផ្នែកនានានៃសេចក្ដីពិចារណា ដែលនៅក្នុងនោះ ពួកគេបានឯកភាពគ្នាថា ដីកាបញ្ជូន រឿងទៅជំនុំជម្រះមានសុពលភាព[65]។

21. ការបកស្រាយណាមួយលើសេចក្ដីពិចារណាទាំងនេះ ដែលបដិសេធការសម្រេចរបស់ចៅក្រម អ.ប.ជ ទាំងប្រាំរូបដែលថាដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព គឺមិនគោរពចំពោះភាពសមហេតុផល និងឱ្យតម្លៃលើទម្រង់ជាជាងខ្លឹមសារ។ ចៅក្រម អ.ប.ជ មានភារកិច្ចអនុវត្តសេចក្ដីសន្និដ្ឋានជាឯកច្ឆន្ទ នេះ តាមរយៈការចេញការកំណត់ជាស្ថាពរមួយ ដែលបញ្ជាក់ថា មាស មុត ត្រូវបានចោទប្រកាន់ និង បញ្ជូនខ្លួនគាត់ទៅជំនុំជម្រះ។

*ម្យ៉ាងវិញទៀត អ.ប.ជ ត្រូវបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះទៅកាន់អង្គជំនុំជម្រះសាលាដំបូង អនុលោមតាមវិធាន ៧៧(១៣)(ខ)*

22. ច្បាប់ អ.វ.ត.ក តម្រូវយ៉ាងច្បាស់លាស់ថា រឿងក្ដី និងសំណុំរឿង ត្រូវបញ្ជូនទៅ អ.ជ.ស.ដ ដើម្បី

---

[62] សំណុំរឿង ០០៤/២-**D359/34** & **D360/43** អនុស្សរណៈថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ របស់ប្រធាន អ.ប.ជ EN 01640437។ **D266/20.1.11** & **D267/25.1.11** អនុស្សរណៈថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ពីប្រធាន អ.ប.ជ កថាខណ្ឌ ៣-៥។

[63] *សូមមើល ឧទាហរណ៍* ឯកសារ **D20/4/4** សេចក្ដីពិចារណារបស់ អ.ប.ជ ស្ដីពីសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ កថាខណ្ឌ ១៣។ ឯកសារ **D174/1/4** សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យពីអំពើបំពារបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មថ្នាក់ជាតិ និង អនុវត្តសហឧក្រិដ្ឋកម្មរួម និង ទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ កថាខណ្ឌ ១៦។ ឯកសារ **D269/4** សេចក្ដីពិចារណារបស់ អ.ប.ជ លើដើមបណ្ដឹងរដ្ឋប្បវេណី កថាខណ្ឌ ៤២។

[64] ឯកសារ **D266/27 & D267/35** សេចក្ដីពិចារណា កថាខណ្ឌ ១១០ ("អនុលោមតាមវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង មតិរបស់សមាជិកផ្សេងៗនៃអង្គបុរេជំនុំជម្រះ ត្រូវបានភ្ជាប់ជាមួយសេចក្ដីពិចារណាទាំងនេះ" (សង្កត់ន័យដើម))។

[65] ឯកសារ **D266/27 & D267/35** សេចក្ដីពិចារណា យោបល់របស់ចៅក្រមជាតិ EN 01666986, FR 01667144, KH 01667332 កថាខណ្ឌទទួលយក ១១៥ យោបល់របស់ចៅក្រមអន្តរជាតិ EN 01667089, FR 01667264, KH 01667480 កថាខណ្ឌទទួលយក ១១៩, ២៦២, ២៨៤ ផ្នែកសម្រេចសេចក្ដី។

ធ្វើការជំនុំជម្រះផ្អែកលើការសម្រេចជាឯកច្ឆន្ទរបស់ អ.ប.ជ ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព។ ប្រសិនបើអង្គជំនុំជម្រះនេះ មិនអើពើចំពោះការសន្និដ្ឋានជាឯកច្ឆន្ទរបស់ខ្លួន យ៉ាងណាក៏ដោយ អ.ប.ជ នៅតែត្រូវបញ្ជូនរឿងក្តីនេះទៅ អ.ជ.ស.ដ ដើម្បីធ្វើការជំនុំជម្រះដែរ។

23. ដោយសារតែដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនត្រូវបានបដិសេធដោយសំឡេងភាគច្រើនលើសលុបរបស់អង្គជំនុំជម្រះនេះ ដូច្នេះសេចក្តីសន្និដ្ឋានជាឯកច្ឆន្ទរបស់ អ.ប.ជ ខ្លួនឯងផ្ទាល់ក្នុងរឿងក្តី ០០៣ និង ០០៤/២ បង្ហាញថា ខ្លួនមានកាតព្វកិច្ចត្រូវបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះទៅកាន់ អ.ជ.ស.ដ អនុលោមតាមវិធាន ៧៧(១៣)(ខ) និង ៧៩(១) នៃវិធានផ្ទៃក្នុង[66]។ ការបរាជ័យរបស់ខ្លួនក្នុងការធ្វើដូច្នេះ គឺជាកំហុសអង្គច្បាប់ ដែលរំលោភមិនត្រឹមតែពាក្យពេចន៍ច្បាស់លាស់នៃវិធានផ្ទៃក្នុងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរំលោភបំពានលើគោលការណ៍ជាមូលដ្ឋានដែលថា កិច្ចដំណើរការនីតិវិធីត្រូវតែគោរពតាមលក្ខខណ្ឌតម្រូវនីត្យានុកូលភាព ភាពត្រឹមត្រូវយុត្តិធម៌ និងប្រសិទ្ធភាព នៃក្របខណ្ឌតុលាការ អ.វ.ត.ក ហើយនីតិវិធីដែលមានស្រាប់ជាធរមានត្រូវតែអនុវត្ត ដើម្បីជៀសវាងការជាប់គាំងផ្នែកនីតិវិធី[67]។ មានតែការបញ្ជូនរឿងក្តី ០០៣ ទៅជំនុំជម្រះប៉ុណ្ណោះ ទើប អ.ប.ជ គោរពតាមអ្វីដែលខ្លួនបានរៀបរាប់ជាឯកច្ឆន្ទថា ជាគោលជំហរស្វ័យប្រវត្តិ"មានលក្ខណៈជាសារវន្ត និងជាកត្តាកំណត់"[68] - ដែលបានលើកឡើងនៅក្នុងមាត្រា ៥(៤) និង ៧(៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក[69] ដែលបានទទួល

---

[66] វិធាន ៧៧(១៣)(ខ) ដែលបង្ហាញថាគោលជំហរស្វ័យប្រវត្តិ នៅពេលដែលបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនត្រូវបានតម្កល់ដោយសំឡេងភាគច្រើនលើសលុប ត្រូវប្តឹងទៅ អ.ជ.ស.ដ ដោយឈរលើមូលដ្ឋាននៃដីកាដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)។ វិធាន ៧៩(១) ចែងថា អ.ជ.ស.ដ ទទួលបណ្តឹងដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះ ពី ស.ច.ស ឬ អ.ប.ជ រួមគ្នាជាមួយវិធាន ១(២) ដែលកំណត់និយមន័យ ស.ច.ស ថាជាការបំពេញកិច្ចរួមគ្នា ឬតែម្នាក់ឯង។ ដោយហេតុថា វិធាន ៧៧(១៣)(ខ) គឺជាវិធានពិសេស (*lex specialis*) ទាក់ទងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចំណុចនេះបង្កើតបានចំណុចដាច់ខាត ទោះបីជាក្នុងករណីដែល អ.ប.ជ ដូចនៅទីនេះ ខកខានមិនអាចរកសំឡេងភាគច្រើនលើសលុបបានសម្រាប់សេចក្តីសម្រេចមួយ លើសុពលភាពនៃដីកាលើកលែងចោទប្រកាន់ក៏ដោយ។

[67] ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា កថាខណ្ឌ ៨៣, ៩៦, ១០១ (ជាឯកច្ឆន្ទ)។ សំណុំរឿង ០០៤/២-**D359/24 & D360/33** សំណុំរឿង ០០៤/២ សេចក្តីពិចារណា កថាខណ្ឌ ៩៥,១០៩, ១១៩ (ជាឯកច្ឆន្ទ)។

[68] ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា កថាខណ្ឌ ៩៨ (ជាឯកច្ឆន្ទ)។ សំណុំរឿង ០០៤/២-**D359/24** & **D360/33** សំណុំរឿង០០៤/២ សេចក្តីពិចារណា កថាខណ្ឌ ១១២ (ជាឯកច្ឆន្ទ)។

[69] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៥(៤) (តម្រូវថា ការស៊ើបអង្កេត*ត្រូវ* បន្តទៀត លើកលែងតែមាត្រា ៧ ត្រូវបានអនុវត្ត។ (គូសបញ្ជាក់បន្ថែម)។ មាត្រា ៧(៤) (តម្រូវថា ប្រសិនបើ អ.ប.ជ មិនអាចដោះស្រាយករណីខ្វែងយោបល់គ្នាដោយសំឡេងភាគច្រើនបានទេ ការស៊ើបអង្កេត ឬការចោទប្រកាន់*ត្រូវ*បន្តទៅមុខ (គូសបញ្ជាក់បន្ថែម))។

ស្គាល់ដោយទាំងរាជរដ្ឋាភិបាលកម្ពុជា និង អង្គការសហប្រជាជាតិ[70] និងដែលបានឆ្លុះបញ្ចាំងនៅក្នុងមាត្រា ២៣ថ្មី នៃច្បាប់ អ.វ.ត.ក[71] - ដែលថា "ការស៊ើបអង្កេតត្រូវតែបន្ត"[72]។ ចំណុចនេះមានន័យថា ក្នុងករណី អ.ប.ជ មិនអាចរកសំឡេងភាគច្រើនលើសលុបដើម្បីបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះបានទេនោះ រឿងក្តីត្រូវបន្តទៅ អ.ជ.ស.ដ។

24. អង្គជំនុំជម្រះនេះបានទទួលស្គាល់យ៉ាងច្បាស់ថា រឿងក្តីដែលមានចំពោះមុខខ្លួននៅលើបណ្តឹងឧទ្ធរណ៍បង្កើតបានជា "ការខ្វែងយោបល់គ្នាដែលមិនត្រូវបានដោះស្រាយ" រវាង ស.ច.ស យ៉ាងហោចណាស់លើបញ្ហាថាតើ មាស មុត ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឬទេ[73]។ អ.ប.ជ បានសន្និដ្ឋានថា ច្បាប់គ្រប់គ្រង អ.វ.ត.ក បានព្យាករយ៉ាងបើកចំហថា ការខ្វែងយោបល់គ្នា រួមទាំងរវាង ស.ច.ស ផង អាចកើតមាននៅក្នុងបរិបទកូនកាត់របស់ អ.វ.ត.ក នេះ និងបានអនុម័តិនីតិវិធីជាក់លាក់ដើម្បីដោះស្រាយ និងសម្រេចបញ្ចប់ការខ្វែងយោបល់បែបដូច្នេះ ដើម្បីជៀសវាងការជាប់គាំងផ្នែកនីតិវិធី[74]។ អ.ប.ជ បានដាក់ការសង្កត់ធ្ងន់លើដំណោះស្រាយវិវាទ*ដ៏មានប្រសិទ្ធភាព* ដោយបានបញ្ជាក់ថា មានគោលជំហរស្វ័យប្រវត្តិច្បាស់លាស់ ដែលផ្តល់នូវវិធីដ៏មានប្រសិទ្ធភាពដើម្បីឲ្យចេញផុតពីការជាប់គាំង

---

[70] ឯកសារ **D267/4.1.5** លិខិតពីអគ្គលេខា អ.ស.ប ផ្ញើជូនលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០០ ត្រូវបានភ្ជាប់ជាមួយនឹងកំណត់ត្រារបស់លោក Hans Corell ផ្ញើជូនអគ្គលេខា កម្មវត្ថុ៖ ការអំពាវនាវបន្ទាន់ពីកម្ពុជា - ជម្រើសក្នុងការដោះស្រាយបញ្ចប់ករណីខ្វែងយោបល់គ្នារវាងចៅក្រមស៊ើបអង្កេត/ព្រះរាជអាជ្ញា ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០០ EN 01614369។ ឯកសារ **D181/2.36** សេចក្តីថ្លែងការដោយអគ្គលេខាធិការរង Hans Corell នៅពេលចាកចេញពីភ្នំពេញ នៅថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០០៣ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៣ EN 01326112។ ឯកសារ **D267/10.1.50** David Scheffer នៅក្នុង M. Cherif Bassiouni (ed), "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា", *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* បោះពុម្ពលើកទី៣ វ៉ុល **III** ឆ្នាំ២០០៨ ទំព័រ ២៤៦។ ចំពោះសេចក្តីលម្អិតនៃឯកសារទាំងអស់នេះ *សូមមើល* ឯកសារ **D267/10** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (D267) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ("ចម្លើយរបស់ ស.ព.អ តបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត") កថាខណ្ឌ ៣១-៣២។

[71] ច្បាប់ អ.វ.ត.ក មាត្រា ២៣ថ្មី ដែលតម្រូវថា ក្នុងករណីមានការខ្វែងយោបល់គ្នារវាង ស.ច.ស ការដែលមិនមានសំឡេងភាគច្រើនលើសលុបដើម្បីរាំងដំណើរការរបស់វាទៅមុខទេនោះ ការស៊ើបអង្កេត*ត្រូវ* បន្តទៀត (គូសបញ្ជាក់បន្ថែម)។

[72] ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា កថាខណ្ឌ ៩៤, ៩៧ (ជាឯកច្ឆន្ទ)។ សំណុំរឿង ០០៤/២-**D359/24 & D360/33** សេចក្តីពិចារណា កថាខណ្ឌ ១០៦-១០៧, ១១១, ១១៧ (ជាឯកច្ឆន្ទ)។

[73] ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា កថាខណ្ឌ ៨៤ (ជាឯកច្ឆន្ទ)។

[74] ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា កថាខណ្ឌ ៩០ (ជាឯកច្ឆន្ទ)។ សំណុំរឿង ០០៤/២-**D359/24 & D360/33** សំណុំរឿង០០៤/២ សេចក្តីពិចារណា កថាខណ្ឌ ១០១ (ជាឯកច្ឆន្ទ)។

ផ្នែកនីតិវិធីណាមួយដែលមាន ដែលបណ្ដាលមកពីការខ្វែងយោបល់គ្នា និងដើម្បីការពារកុំឲ្យមានការជាប់គាំងផ្នែកនីតិវិធី ដែលនឹងប៉ះពាល់ដល់ប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធី និងរារាំងមិនឲ្យមានយុត្តិធម៌ព្រហ្មទណ្ឌប្រកបដោយប្រសិទ្ធភាព[75]។

25. ជាងនេះទៀត មានតែការអនុវត្តគោលជំហរស្វ័យប្រវត្តិដែល"ការស៊ើបអង្កេតត្រូវបន្តទៀត" នៅចំពោះមុខការខ្វែងយោបល់គ្នាដែលមិនត្រូវបានដោះស្រាយប៉ុណ្ណោះ ទើប អ.ប.ជ អាចធានាបានថា អ.វ.ត.ក បំពេញបាននូវវត្ថុបំណង និងគោលបំណងនៃកិច្ចព្រមព្រៀង អ.វ.ត.ក និង ច្បាប់ អ.វ.ត.ក ដែលត្រូវ "*[នាំយកមក]កាត់សេចក្ដី* នូវមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យនិងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម"[76]។ ការណ៍នេះចាំបាច់ត្រូវអនុវត្តកាតព្វកិច្ចអន្តរជាតិរបស់កម្ពុជា ក្នុងការស៊ើបអង្កេត និងកាត់សេចក្ដីឧក្រិដ្ឋកម្មនានាក្នុងសម័យខ្មែរក្រហម[77] ដោយការធ្វើការស៊ើបអង្កេត និងការចោទប្រកាន់ត្រឹមត្រូវ និងដ៏មានប្រសិទ្ធភាពចំពោះឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក[78]។

26. ហេតុដូច្នេះ អ.ប.ជ បានគូសបញ្ជាក់ម្ដងហើយម្ដងទៀតថា ការខ្វែងយោបល់គ្នានេះមិនគួរនៅបន្តគេចចេញ ឬមិនទទួលយកដំណោះស្រាយប្រកបដោយប្រសិទ្ធភាពនោះឡើយ[79]។ ក្នុងន័យនេះ អង្គជំនុំជម្រះនេះបានសង្កត់ធ្ងន់ជាឯកច្ឆន្ទថា៖

> គោលការណ៍ដែលមានលក្ខណៈសារវន្ត និងកំណត់សម្រេចដូចជា គោលជំហរស្វ័យប្រវត្តិនេះ គឺមិនអាចលុបចោល ឬដកចេញនូវស្ថានទម្ងន់ និងអានុភាពពេញលេញទាំងស្រុងរបស់វា ដោយការរៀបចំការបកស្រាយ ដែលជាការកេងចំណេញលើភាពមិនច្បាស់

---

[75] ឯកសារ **D266/27 & D267/35** សេចក្ដីពិចារណា កថាខណ្ឌ ៩៦-៩៧, ១០០-១០១ (ជាឯកច្ឆន្ទ)។ សំណុំរឿង ០០៤/២-**D359/24** & **D360/33** សំណុំរឿង០០៤/២ សេចក្ដីពិចារណា កថាខណ្ឌ ១១១, ១១៤, ១១៩ (ជាឯកច្ឆន្ទ)។

[76] កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១។ ច្បាប់ អ.វ.ត.ក មាត្រា ១។

[77] សំណុំរឿង ០០៤/២-**D359/24** & **D360/33** សំណុំរឿង០០៤/២ សំណុំរឿង០០៤/២ សេចក្ដីពិចារណា កថាខណ្ឌ ៥៧, ១១០ (ជាឯកច្ឆន្ទ)។ *សូមមើលផងដែរ* សំណុំរឿង០០៤/១-**D308/3/1/20** សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ("សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយសំណុំរឿង០០៤/២១) កថាខណ្ឌ ៧៥ (ជាឯកច្ឆន្ទ)។

[78] សំណុំរឿង ០០៤/២-**D359/24** & **D360/33** សំណុំរឿង០០៤/២ សេចក្ដីពិចារណា កថាខណ្ឌ ១១០ (ជាឯកច្ឆន្ទ)។

[79] ឯកសារ **D266/27 & D267/35** សេចក្ដីពិចារណា កថាខណ្ឌ ១០១ (ជាឯកច្ឆន្ទ)។ សំណុំរឿង ០០៤/២-**D359/24** & **D360/33** សំណុំរឿង០០៤/២ សេចក្ដីពិចារណា កថាខណ្ឌ ១១៩, ១២៣ (ជាឯកច្ឆន្ទ)។

លាស់ដែលអាចមាននៅក្នុងច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង ដើម្បីធ្វើឲ្យគោលការណ៍ស្នូលនៃកិច្ចព្រមព្រៀង អ.វ.ត.ក នេះទៅជាអសារឥតន័យនោះឡើយ។ ការសន្និដ្ឋានផ្សេងពីនេះ នឹងនាំឲ្យមានលទ្ធផលគតិយុត្តិមួយដែលមិនសមហេតុផលទាល់តែសោះ ហើយនាំឲ្យមានការរំលោភបំពាន ទាំងទៅលើច្បាប់អន្តរជាតិ និងច្បាប់កម្ពុជា[80]។

27. ការសន្និដ្ឋានជាឯកច្ឆន្ទរបស់ អ.ប.ជ បង្ហាញថា ក្នុងនាមជាស្ថាប័នដែលអនុវត្ត "អំណាចចុងក្រោយ" ឬជា "ស្ថាប័នដែលត្រួតពិនិត្យ" នៅដំណាក់កាលស៊ើបអង្កេត[81] អង្គជំនុំជម្រះនេះ*មានកាតព្វកិច្ច* ដោះស្រាយការខ្វែងយោបល់ទាំងអស់នោះរវាង ស.ច.ស មិនចំពោះថា តើបញ្ហាទាំងនោះនៅចំពោះមុខខ្លួនក្នុងទម្រង់ជាយន្តការខ្វែងយោបល់ផ្លូវការ[82] ឬតាមវិធីបណ្តឹងឧទ្ធរណ៍របស់ភាគីនោះទេ។ នៅក្នុងពាក្យពេចន៍ផ្ទាល់របស់ អ.ប.ជ "បើតាមកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក មុខងារចម្បងដែលផ្តល់ជូនអង្គបុរេជំនុំជម្រះ គឺច្បាស់លាស់អំពីយន្តការដើម្បីដោះស្រាយជាស្ថាពរចំពោះការខ្វែងយោបល់គ្នារវាង [...] [ស.ច.ស]"[83] ដោយការប្រើប្រាស់គោលជំហរស្វ័យប្រវត្តិ ប្រសិនបើចាំបាច់។ ក្នុងន័យនោះ អ.ប.ជ បានគូសបញ្ជាក់រួចហើយថា ខ្លួនអាចអនុវត្តអំណាចរបស់ខ្លួន ដែលមិនមានចែងជាក់លាក់នៅ

---

[80] ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា កថាខណ្ឌ 98 (ជាឯកច្ឆន្ទ យោងសំអាងខាងក្នុងត្រូវបានដកចេញ)។ សំណុំរឿង ០០៤/២-**D359/24** & **D360/33** សំណុំរឿង០០៤/២ សេចក្តីពិចារណា កថាខណ្ឌ ១១២ (ជាឯកច្ឆន្ទ)។

[81] សំណុំរឿង ០០៤/២-**D359/24** & **D360/33** សេចក្តីពិចារណា កថាខណ្ឌ ៤៩, ៥៤ (ជាឯកច្ឆន្ទ)។ សំណុំរឿង ០០៤/១-**D308/3/1/20** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ សំណុំរឿង០០៤/១ កថាខណ្ឌ ២៨ (ជាឯកច្ឆន្ទ)។

[82] សំណុំរឿង ០០៤/២-**D359/24** & **D360/33** សំណុំរឿង០០៤/២ សេចក្តីពិចារណា កថាខណ្ឌ ១១៧ (ជាឯកច្ឆន្ទ)។ ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា ជើងទំព័រ ១៧៩ (ជាឯកច្ឆន្ទ)។ ក្នុងវិធីដូចគ្នានេះដែរ អ.ប.ជ នៅក្នុងសេចក្តីពិចារណារបស់ខ្លួន ទាក់ទងនឹងករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា លើបញ្ហាថាតើត្រូវប្តឹងរឿងក្តី ០០៣ និង ០០៤ ទៅ ស.ច.ស ឬទេ បានបញ្ជាក់ជាឯកច្ឆន្ទថា ការបរាជ័យមិនអាចឈានដល់សំឡេងភាគច្រើនលើសលុបសម្រាប់សេចក្តីសម្រេចមួយដើម្បីរារាំងការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ នាំឲ្យចាប់ផ្តើមប្រើយន្តការស្វ័យប្រវត្តិ ក្នុងមាត្រា ៧(៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងមាត្រា ២០ នៃច្បាប់ អ.វ.ត.ក ដែលចែងថា "ការចោទប្រកាន់ត្រូវបន្ត" មានន័យថា ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ គួរត្រូវបញ្ជូនទៅ ស.ច.ស។ *សូមមើល* ឯកសារ **D1/1.3** ការពិចារណារបស់ អ.ប.ជ លើករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា កថាខណ្ឌ១៧, ៤៥ (ដូចដែលបានកែតម្រូវនៅក្នុងឯកសារ **D1/1.2** ការកែតម្រូវ)។ អង្គជំនុំជម្រះនេះបានគូសបញ្ជាក់ទំនាក់ទំនងគ្នារវាងសេចក្តីសម្រេចនេះ និងគោលជំហរស្វ័យប្រវត្តិ ដែលអាចអនុវត្តបានចំពោះករណីខ្វែងយោបល់គ្នារវាង ស.ច.ស។ (*សូមមើល* សំណុំរឿង ០០៤/២-**D359/24** & **D360/33** សំណុំរឿង០០៤/២ សេចក្តីពិចារណា កថាខណ្ឌ ១១៧ ជើងទំព័រ ១៨៨ (ជាឯកច្ឆន្ទ)។

[83] ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា កថាខណ្ឌ ៩០, ជើងទំព័រ ១៧៩ (ជាឯកច្ឆន្ទ)។ សំណុំរឿង ០០៤/២-**D359/24** & **D360/33** សំណុំរឿង០០៤/២ សេចក្តីពិចារណា កថាខណ្ឌ ១០១, ១១៧ (ជាឯកច្ឆន្ទ)។

ក្នុងក្របខណ្ឌច្បាប់ អ.វ.ត.ក ដែល - ដូចក្នុងស្ថានភាពបច្ចុប្បន្ន - ស្របទៅនឹង (i) មុខងារដែលបានប្រគល់ឲ្យខ្លួនតាមច្បាប់ អ.វ.ត.ក ក្នុងផលប្រយោជន៍នៃយុត្តិធម៌[84] (ii) កាតព្វកិច្ចរបស់ខ្លួន ស្របតាមវិធាន ២១ ដើម្បី "ការពារផលប្រយោជន៍របស់ជនត្រូវចោទ និងធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធី "ដោយយុត្តិធម៌ និងគោរពគោលការណ៍ចំពោះមុខ""[85] និង (iii) តម្រូវការចាំបាច់ក្នុងការធានាបាននូវកិច្ចការរដ្ឋបាលតុលាការដែលល្អ និងត្រឹមត្រូវយុត្តិធម៌[86]។

28. នៅតុលាការពិសេសក្នុងសាធារណរដ្ឋអាហ្វ្រិកកណ្តាល ដែលជាតុលាការកូនកាត់មួយផ្សេងទៀតស្ថិតនៅក្នុងប្រព័ន្ធស៊ីវិល គឺ *Chambre d'accusation spéciale* - អង្គជំនុំជម្រះសាលាឧទ្ធរណ៍មុនការជំនុំជម្រះដូចគ្នានឹង អ.ប.ជ ដែរ - បំពេញតួនាទីស្រដៀងគ្នានេះក្នុងការដោះស្រាយវិវាទរវាងសហចៅក្រមស៊ើបអង្កេតដែលមានសិទ្ធិអំណាចស្មើគ្នា។ នៅក្នុងរឿងក្តីនោះ ដូចគ្នានឹងនៅ អ.វ.ត.ក ដែរ ដំណោះស្រាយឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាពដោយ *Chambre d'accusation spéciale* ត្រូវបានគ្រោងទុក[87]។

29. ជាចុងក្រោយ ការទទួលស្គាល់នូវកាតព្វកិច្ចសម្រាប់អង្គជំនុំជម្រះ ក្នុងការផ្តល់នូវសច្ចភាពផ្លូវច្បាប់ និងការកំណត់ជាស្ថាពរលើបញ្ហានានានៅចំពោះមុខខ្លួន ការអនុវត្តរបស់តុលាការ និងសាលាក្តីអន្តរជាតិផ្សេងទៀត បង្ហាញថា មានអត្ថិភាពនៃ*លក្ខខណ្ឌតម្រូវ* ក្នុងការអនុវត្តគោលជំហរស្វ័យប្រវត្តិ ក្នុងករណីដែលសំឡេងភាគច្រើនដែលត្រូវការមិនអាចរកបាន និងថា មិនអនុញ្ញាតឲ្យទុករឿងក្តីស្ថិតក្នុងភាពមិនច្បាស់លាស់ផ្នែកតុលាការឡើយ។ លក្ខខណ្ឌតម្រូវសំឡេងភាគច្រើនលើសលុបរបស់ អ.វ.ត.ក បង្ហាញបញ្ហាដ៏លំបាកដូចគ្នាទៅនឹងអង្គជំនុំជម្រះដែលមានចំនួនចៅក្រមគូដែរ ក្នុងន័យដែលថា តាមលក្ខណៈ

---

[84] សំណុំរឿង ០០៤/២-**D359/24** & **D360/33** សំណុំរឿង០០៤/២ សេចក្តីពិចារណា កថាខណ្ឌ ៤៥-៤៦, ៥១ (ជាឯកច្ឆន្ទ)។

[85] សំណុំរឿង ០០៤/២-**D359/24** & **D360/33** សំណុំរឿង០០៤/២ សេចក្តីពិចារណា កថាខណ្ឌ ៤៦, ៥១ (ជាឯកច្ឆន្ទ)។

[86] សំណុំរឿង ០០៤/២-**D359/24** & **D360/33** សំណុំរឿង០០៤/២ សេចក្តីពិចារណា កថាខណ្ឌ ៥១ (ជាឯកច្ឆន្ទ)។

[87] សាធារណរដ្ឋអាហ្វ្រិកកណ្តាល Loi Organique No. 15.003 Portant Création, Organisation et Fonctionnement de la Cour Pénale Spéciale, ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៥ មាត្រា ១១ (សភាស៊ើបសួរមានការិយាល័យចំនួនបី។ ការិយាល័យនីមួយៗមានចៅក្រមជាតិម្នាក់ និងចៅក្រមអន្តរជាតិម្នាក់។ មាត្រា ១២ (សភាបញ្ជូនរឿងទៅជំនុំជម្រះពិសេស មានចៅក្រមបីរូប៖ ចៅក្រមអន្តរជាតិពីរនាក់ និងចៅក្រមជាតិម្នាក់ សម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាចេញដោយការិយាល័យស៊ើបសួរ។) មាត្រា ៤២ (ក្នុងករណីដែលមានការខ្វែងយោបល់គ្នារវាងចៅក្រមស៊ើបសួរនៃការិយាល័យតែមួយ ចំណុចដែលខ្វែងគ្នានោះត្រូវធ្វើកំណត់ហេតុក្នុងរបាយការណ៍មួយ និងត្រូវបញ្ជូន តាមរយៈអយ្យការពិសេស ទៅកាន់សភាបញ្ជូនរឿងទៅជំនុំជម្រះពិសេស ដែលមានរយៈពេលប្រាំថ្ងៃក្នុងការសម្រេច។ សេចក្តីសម្រេចរបស់សភាបញ្ជូនរឿងទៅជំនុំជម្រះពិសេសចងកាតព្វកិច្ចសហចៅក្រមស៊ើបអង្កេត)។

គិណិតវិទ្យាវាអាចថា សំឡេងគាំទ្រភាគច្រើនលើសលុបដែលត្រូវការមិនអាចទទួលបាន។ នៅពេលពិនិត្យមើលតាមវិធីនេះ គេច្បាស់ណាស់ថាការសន្និដ្ឋានជាឯកច្ឆន្ទអំពីដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាពដោយឡែកសម្រាប់ពេលបច្ចុប្បន្ននេះ ស្ថានភាពដែលជួបប្រឈមដោយ អ.ប.ជ នៅក្នុងរឿងក្ដីនេះមិនមែនពិសេសមានតែមួយនោះទេ[88]។ ទោះបីជាយ៉ាងណា សម្រាប់ហេតុផលជាក់ស្ដែង យុត្តាធិការអន្តរជាតិភាគច្រើនមានអង្គគណៈកម្មការដែលមានចំនួនសេស មិនមានយុត្តាធិការអន្តរជាតិច្រើនទេដែលមាន ឬអាចមាន ចំនួនចៅក្រមគត់គូ[89]។ គ្រប់រឿងក្ដីមួយៗនៃរឿងក្ដីទាំងនេះ ក្របខណ្ឌច្បាប់នៃសាលាក្ដីពាក់ព័ន្ធ មានយន្តការស្វ័យប្រវត្តិដើម្បីអនុវត្ត នៅពេលសំឡេងភាគច្រើនដែលត្រូវការ

---

[88] ហេតុដូច្នេះ ស.ព.អ សូមជំទាស់ទៅនឹងចៅក្រមអន្តរជាតិ អ.ប.ជ នៅពេលដែលពួកគាត់ផ្ដល់យោបល់ថា "វិធានស្ដីពីសំឡេងភាគច្រើន និងគោលជំហរស្វ័យប្រវត្តិ ដែលបានគ្រោងទុកដោយវិធានផ្ទៃក្នុង គឺជាលក្ខណៈពិសេស របស់ អ.វ.ត.ក ដែលអាចនាំឱ្យអង្គជំនុំជម្រះមិនអាចឈានដល់ការសម្រេចមួយលើបញ្ហាជាក់លាក់បាន។" *សូមមើល* ឯកសារ **D266/20.1.10** & **D267/25.1.10** សំណុំរឿង ០០៤/២-អនុស្សរណៈអន្តរការិយាល័យពីចៅក្រម អ.ប.ជ ចៅក្រម Olivier Beauvallet និង Kang Jin Baik មានចំណងជើងថា "ការបញ្ជូនសំណុំរឿង ០០៤/២" ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ កថាខណ្ឌ ៣។ តាមពិតនោះមានគោលជំហរស្វ័យប្រវត្តិផ្សេងទៀតជាច្រើន ដែលបានសរសេរនៅក្នុងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ទាក់ទងទៅនឹងសេចក្ដីសម្រេចរបស់ **<u>អ.ប.ជ</u>** (វិធាន ១១(៥) (ការចុះបញ្ជីមេធាវីសម្រាប់ការពារជនក្រីក្រ ដោយផ្អែកគាំពារការការពារក្ដី) វិធាន ២២(១)(ច) (ការចុះបញ្ជីមេធាវីបរទេសជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (BAKC)) វិធាន ២៣*ស្ទួនបី*(ង) (ការអនុញ្ញាតទទួលយកសមាគមជនរងគ្រោះដោយផ្អែកគាំពារជនរងគ្រោះ) **អ.ជ.ស.ដ** (វិធាន ៩៨(៤)) **អ.ជ.ត.ក** (វិធាន ១០៨(*ស្ទួន៤*), និង **អង្គជំនុំជម្រះពិសេស** (វិធាន ៣៤(១១))។

[89] *សូមមើលឧទាហរណ៍* **<u>តុលាការយោធាអន្តរជាតិ នៅ Nuremberg ("IMT"):</u>** ធម្មនុញ្ញនៃតុលាការយោធាអន្តរជាតិ ទីក្រុងឡុងដ៍ ថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៤៥ ("ធម្មនុញ្ញទីក្រុងឡុងដ៍") មាត្រា ២, ៤(ក)។ **<u>តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា ("IMTFE"):</u>** ធម្មនុញ្ញ IMFTE,ទីក្រុងតូក្យូ ថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៤៦ មាត្រា ២, ៤(ក)។ **<u>តុលាការយោធា ស.រ.អ នៅ Nuremberg ("USMT"):</u>** រដ្ឋាភិបាលយោធា – ប្រទេសអាល្លឺម៉ង់ តំបន់សហរដ្ឋ បញ្ញាលេខ ៧៖ ការចាត់តាំង និងអំណាចនៃតុលាការយោធាពិតប្រាកដ ថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៤៦ ("បញ្ញាលេខ ៧") មាត្រា II(ខ), II(ឆ)។ **<u>តុលាការយុត្តិធម៌អន្តរជាតិ ("ICJ") និង PCIJ:</u>** លក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៤៦ ("លក្ខន្តិកៈ ICJ") មាត្រា ៣(១), ២៣-២៦, ២៩, ៣១។ សម្ព័ន្ធប្រជាជាតិ លក្ខន្តិកៈនៃតុលាការយុត្តិធម៌អន្តរជាតិអចិន្ត្រៃយ៍ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩២០ ("លក្ខន្តិកៈ PCIJ") ដូចដែលបានកែប្រែនៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩២៦ មាត្រា ២៤-២៧, ២៩។ **<u>តុលាការសិទ្ធិមនុស្សអន្តរអាមេរិកកាំង ("IACtHR")</u>**: លក្ខន្តិកៈរបស់តុលាការសិទ្ធិមនុស្សអន្តរអាមេរិកកាំង (លក្ខន្តិកៈ IACtHR") ចុះថ្ងៃទី១ ខែតុលា ឆ្នាំ១៩៧៩ មាត្រា ៤, ១០, ២៣។ **<u>តុលាការយុត្តិធម៌ និងសិទ្ធិមនុស្សអាហ្វ្រិក ("ACJHR"):</u>** លក្ខន្តិកៈនៃតុលាការយុត្តិធម៌ និងសិទ្ធិមនុស្សអាហ្វ្រិក ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៨ ("ពិធីសារ ACHR") មាត្រា ៣, ១៦-១៩, ២១។ **<u>សាលាក្ដីអន្តរជាតិសម្រាប់ច្បាប់សមុទ្រ ("ITLOS")</u>**: លក្ខន្តិកៈរបស់ ITLOS, ឧបសម្ព័ន្ធ VI ភ្ជាប់ទៅនឹងអនុសញ្ញា អ.ស.ប ស្ដីពីច្បាប់សមុទ្រ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨២ ("លក្ខន្តិកៈ ITLOS") មាត្រា ២, ១៣-១៥, ១៧, ៣៥-៣៦។

មិនអាចរកបាន[90] និងក្នុងពេលដែលត្រូវតែអនុវត្តដោយចៅក្រម។ *គ្មានករណីណាមួយទាល់តែសោះ* ដែលលទ្ធផលខ្វែងគ្នានាំឱ្យមានការលើកលែងចោទប្រកាន់ជាស្វ័យប្រវត្តិ។

30. វិធាន ៧៧(១៣)(ខ) និងគោលជំហរស្វ័យប្រវត្តិក៏មិនខុសគ្នាដែរ ហើយក៏មិនបានបើកផ្លូវឱ្យចៅក្រមជាតិមើលរំលងគោលជំហរទាំងនោះដែរ។ តាមពិត ដូចដែល ស.ព.អ បានពន្យល់យ៉ាងលម្អិតនៅក្នុងសេចក្តីសន្និដ្ឋានពីមុន ការលើកលែងចោទប្រកាន់រឿងក្តី ០០៣ *មិន* ត្រូវបានកំណត់ដោយគោលការណ៍សច្ចធាណ៍នៃនិរទោស[91] ឬ*វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* នោះទេ[92] ជាពិសេស ក្នុងករណីដូចនៅទីនេះ ដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានតម្កល់ដោយសំឡេងភាគច្រើនលើសលុប។ មាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[93] កំណត់មូលហេតុនៃការរលត់បណ្តឹងអាជ្ញានៅក្នុងយុត្តាធិការរបស់តុលាការហួសពីការលើកលែងចោទប្រកាន់ ឬការដោះលែងឱ្យរួចខ្លួនផ្អែកលើអង្គ

---

[90] ក្នុងករណីដែលថា សំឡេងគាំទ្រត្រូវបានបែងចែកជាលេខគត់គូ គោលជំហរស្វ័យប្រវត្តិខាងក្រោមត្រូវបានអនុវត្ត៖ **IMT**: ធម្មនុញ្ញទីក្រុងឡុងដ៍ មាត្រា ៤(គ) (សំឡេងគាំទ្ររបស់ប្រធានជាកត្តាកំណត់តែនៅពេលដែលការផ្តន្ទាទោស និងការកំណត់ទោសត្រូវបានដាក់តែដោយសំឡេងគាំទ្រវិជ្ជមាននៃយ៉ាងហោចណាស់សមាជិកបីរូបរបស់សាលាក្តី)។ **IMTFE**: ធម្មនុញ្ញរបស់ IMTFE មាត្រា ៤(ខ) (សំឡេងគាំទ្ររបស់ប្រធានជាកត្តាកំណត់)។ **USMT**: បញ្ញាលេខ ៧ មាត្រា II(ជ) (សមាជិកដែលជាប្រធានប្រកាស់សេចក្តីសម្រេចទុកជាមោឃៈ)។ **ICJ** និង **PCIJ**: លក្ខន្តិកៈ ICJ មាត្រា ៥៥(១)-(២) (ប្រធាន (ឬអ្នកជំនួស) មានសន្លឹកឆ្នោតបន្ថែម) លក្ខន្តិកៈ PCIJ មាត្រា ៥៥(១)-(២) (ប្រធាន ឬអនុរបស់គាត់ មានសន្លឹកឆ្នោតបន្ថែម)។ **IACtHR**: លក្ខន្តិកៈ IACtHR មាត្រា២៣(២)-(៣)(ប្រធានបោះសន្លឹកឆ្នោតសម្រេច)។ **ACJHR**: លក្ខន្តិកៈ ACHR មាត្រា ៤២(១)-(២) (ប្រធានមានសន្លឹកឆ្នោតបន្ថែម)។ **ITLOS**: លក្ខន្តិកៈ ITLOS មាត្រា ២៩(១)-(២) (ប្រធាន (ឬអ្នកជំនួស) មានសន្លឹកឆ្នោតបន្ថែម)។

[91] *ផ្ទុយពី* ឯកសារ **D266/27** & **D267/35** សេចក្តីពិចារណា យោបល់របស់ចៅក្រមជាតិ កថាខណ្ឌ ១១៦។ សច្ចធារណ៍នៃនិរទោសធានាថា មុនពេលការដាក់ទោសព្រហ្មទណ្ឌអាចធ្វើទៅបាន បន្ទុកស្ថិតនៅលើភាគីចោទប្រកាន់ ក្នុងការបង្ហាញភ័ស្តុតាងបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទឱ្យហួសពីវិមតិសង្ស័យ *នៅពេលជំនុំជម្រះ*។ វានៅតែមិនរំខាន លុះត្រាតែ និងរហូតទាល់តែ មាស មុត ត្រូវបានផ្តន្ទាទោសដោយសំឡេងភាគច្រើនលើសលុបរបស់ចៅក្រម អ.ជ.ស.ដ។ *សូមមើល* វិធាន ៨៧(១), ៩៨(៤)។ សំណុំរឿង ០០៤/២-**D359/24** & **D360/33** សំណុំរឿង០០៤/២ សេចក្តីពិចារណា កថាខណ្ឌ ១៦៣ (ជាឯកច្ឆន្ទ)។

[92] **D267/10** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ៣៩-៥០។ ឯកសារ **D266/6** & **D267/11** ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងចម្លើយរបស់ មាស មុត ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត (D266) ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៩ កថាខណ្ឌ ៦៧-៧១។

[93] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧មាត្រា ៧។ ផ្ទុះបញ្ចាំងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ៦។

សេចក្តី[94] ត្រឹមមរណភាពនៃជនជាប់ចោទ ការផុតអាជ្ញាយុកាល ការទទួលបានការលើកលែងទោស និរាករណ៍នៃច្បាប់ និង*អាជ្ញាអស់ជំនុំ*[95]។ មិនមានចំណុចណាមួយក្នុងចំណោមចំណុចខាងលើនេះ អនុវត្តបានចំពោះរឿងក្តី ០០៣ ដែលមានដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព សម្រាប់ឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ហើយដែល អ.ជ.ត.ក និង អ.ជ.ស.ដ ទាំងអស់គ្នាបានសម្រេចថា អ.វ.ត.ក មិនមានសិទ្ធិអំណាចបង្គាប់ឲ្យរលត់បណ្តឹងអាជ្ញាដោយមូលហេតុណាមួយផ្សេងពីនេះទេ[96]។

31. ហេតុដូច្នេះ ការអនុវត្តគោលការណ៍ទាំងអស់នេះចំពោះរឿងក្តី ០០៣ បង្ហាញថា សូម្បីតែ អ.ប.ជ មិនអើពើចំពោះសេចក្តីសន្និដ្ឋានជាឯកច្ឆន្ទរបស់ខ្លួនដែលថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព (ដែលខ្លួនមិនអាចធ្វើដូច្នេះបាន) នៅពេលដែលបន្ទាប់ពីនីតិវិធីបណ្តឹងឧទ្ធរណ៍ទាំងអស់ត្រូវបានបញ្ចប់ហើយ អ.ប.ជ មិនអាចបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយសំឡេងភាគច្រើនលើសលុបទេ នោះ អ.ប.ជ មានភារកិច្ចត្រូវអនុវត្តគោលជំហរស្វ័យប្រវត្តិ និងត្រូវបញ្ជូនរឿងក្តី០០៣ ទៅជំនុំជម្រះ។

## V. សេចក្តីសន្និដ្ឋាន

32. ប្រសិនបើ អ.ប.ជ ខកខានមិនបានអនុវត្តភារកិច្ចតុលាការរបស់ខ្លួនស្របតាមច្បាប់ ភាពសមហេតុផល និងយុត្តិធម៌ទេ នោះអង្គបុរេជំនុំជម្រះធ្វើឲ្យយន្តការតុលាការ អ.វ.ត.ក មានអពលានុភាព និងអាចនាំឲ្យមានការផ្តល់ឲ្យ មាស មុត នូវអត្ថប្រយោជន៍និទណ្ឌភាពមិនត្រឹមត្រូវយុត្តិធម៌ ចំពោះឧក្រិដ្ឋកម្មដ៏អាក្រក់បំផុត ទាំងក្នុងចំនួន និងទាំងប្រភេទ ដែលបានចោទប្រកាន់ប្រឆាំងនឹងគាត់។ មាស មុត

[94] នៅដំណាក់កាលមុនការជំនុំជម្រះ ស.ច.ស អាចចេញដីកាសម្រេចលើកលែងចោទប្រកាន់តាមមូលហេតុដូចបានរាយឈ្មោះនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (CCCP) មាត្រា ២៤៧ (*សូមមើលផងដែរ* វិធាន ៦៧(៣)។ ជនជាប់ចោទអាចត្រូវបានដោះលែងឲ្យរួចខ្លួននៅពេលសវនាការ ឬតាមបណ្តឹងឧទ្ធរណ៍ក្រោម CCCP មាត្រា ៣៥០, ៤០៥, ៤៣៩-៤៤១ (*សូមមើលផងដែរ* វិធាន ៨៧(១), ៩៨(៣)-(៤), ១១១(៤))។

[95] *សូមមើលបន្ថែមទៀត* ឯកសារ **D267/10** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ៥០។

[96] សំណុំរឿង០០២-**E138/1/10/1/5/7** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ កថាខណ្ឌ ៣៨។ សំណុំរឿង ០០២-**E116** សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារ E51/3, E82, E88 និង E92) ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌ ១៦-១៧ (បានសន្និដ្ឋានថា កិច្ចដំណើរការនីតិវិធី អ.វ.ត.ក អាចរលត់បានតែតាមវិធាន ៨៩(១)(ខ) ប៉ុណ្ណោះ ផ្អែកលើមូលដ្ឋានដ៏មានកម្រិតមួយ ដែលមានចែងនៅក្នុងមាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា)។

ទទួលស្គាល់ថា ឧក្រិដ្ឋកម្មដែលគាត់ត្រូវបានចោទប្រកាន់ គឺជា "ឧក្រិដ្ឋកម្មដែលជាការព្រួយបារម្ភបំផុតចំពោះសហគមន៍អន្តរជាតិ"[97]។ គាត់មិនបានជំទាស់ទៅនឹងសេចក្ដីសន្និដ្ឋានផ្នែកអង្គហេតុ ឬអង្គច្បាប់ណាមួយនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទាក់ទងនឹងឧក្រិដ្ឋកម្មទាំងអស់នោះទេ ហើយក៏មិនជំទាស់ទៅនឹងការសន្និដ្ឋានរបស់ ស.ច.ស.អ ដែលថា អ.វ.ត.ក មានយុត្តាធិការលើរូបគាត់នោះដែរ។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលនេះត្រូវបានតម្កល់ដោយចៅក្រមគ្រប់រូបគឺទាំងប្រាំរូបនៃ អ.ប.ជ ហើយមិនមានសំឡេងភាគច្រើនលើសលុប ដើម្បីតម្កល់សុពលភាពដីកាលើកលែងចោទប្រកាន់ឡើយ។ តាមពិត ចៅក្រម អ.ប.ជ ដែលបានពិនិត្យមើលខ្លឹមសារនៃដីកាលើកលែងចោទប្រកាន់ បានរកឃើញថាដីកានោះ "មិនពេញលេញ" យ៉ាងច្បាស់ក្រឡែត ដោយបានមើលរំលងភស្តុតាងដែលបានប្រមូលក្នុងរយៈពេលប្រាំពីរឆ្នាំ ដែលត្រូវបានដាក់ក្នុងសំណុំរឿងតាំងពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ និងការចោទប្រកាន់ផ្នែកអង្គហេតុជាច្រើនទៀតដែល ស.ព.អ បានប្ដឹងទៅ ស.ច.ស.ជ យ៉ាងត្រឹមត្រូវតាមច្បាប់។

33. យុត្តិធម៌មិនត្រូវបានកំណត់និយមន័យថា ជាអ្វីក៏ដោយដែលផ្ដល់អត្ថប្រយោជន៍បំផុតដល់ជនជាប់ចោទនោះទេ។ យុត្តិធម៌លាតសន្ធឹងដល់គ្រប់ភាគីទាំងអស់ និងដល់សិទ្ធិរបស់ជនរងគ្រោះជាបឋម និងជនរងគ្រោះបន្ទាប់បន្សំ ដើម្បីឱ្យគណនេយ្យភាពនោះត្រូវបានកំណត់តាមផ្លូវតុលាការ ដោយចៅក្រមឯករាជ្យ និងអនាគតិ ដែលបំពេញកិច្ចផ្អែកលើតែសេចក្ដីសុចរិត និងការអនុវត្តសមហេតុសមផលចំពោះច្បាប់ និងអង្គហេតុ។

## VI. **ដំណោះស្រាយដែលស្នើសុំ**

34. សម្រាប់មូលហេតុដូចបានគូសបញ្ជាក់ខាងលើ សហព្រះរាជអាជ្ញាអន្តរជាតិសូមស្នើដោយគោរពឱ្យអង្គបុរេជំនុំជម្រះ៖

ក. បិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃរឿងក្ដី ០០៣ ដោយការផ្ដល់នូវការសម្រេចជាស្ថាពរមួយដែលឯកភាពគ្នា ដែលបញ្ជាក់ថា មាស មុត ត្រូវបានចោទប្រកាន់ និងបង្គាប់ឱ្យនាំខ្លួនគាត់ទៅជំនុំជម្រះ; និង

ខ. ចាត់វាល់វិធានការរដ្ឋបាលដែលចាំបាច់ទាំងអស់ ដើម្បីបញ្ជូនជាបន្ទាន់នូវសេចក្ដីពិចារណាដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃរឿងក្ដី ០០៣ និងសំណុំរឿងដែលនៅសេសសល់ ទៅកាន់

[97] ឯកសារ **D267/4** បណ្ដឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩ កថាខណ្ឌ ៤៤។

អង្គជំនុំជម្រះសាលាដំបូង។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ | **លោកស្រី** **Brenda J HOLLIS** សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |